ក្រុមគ្រួសារបព្វជិតបព្វជិតា

# ព្រះសហគមន៍កាតូលិក

# កម្ពុជា

# ក្រុមដូនជីសំខាត់កាមែល




## ប្រវត្តិក្រុម ៖

តាំងពីសតវត្សទី ១១ នៃគ.ស. ក្រុមគ្រីស្តបរិស័ទបានមករស់នៅតាមរូងភ្នំ នៃភ្នំកាមែល នៅប្រទេសអ៊ីស្រាអែល ដើម្បីធ្វើវិបស្សនាក្នុងលក្ខណៈជាតាបស។ ក្រោយមកពួកគេក៏ចាប់ផ្តើមបង្រួបបង្រួមគ្នាដោយទទួលវិន័យនៅឆ្នាំ១២០៩គ.ស. ប៉ុន្តែនៅសតវត្សទី ១៣នៃគ.ស. កងទ័ពអ៊ីស្លាម បានបណ្តេញក្រុមនេះចេញពីប្រទេសទៅទ្វីបអឺរ៉ុប នៅទីនោះគេក៏ចាប់ផ្តើមបង្កើតអារាមដូនជីសំងាត់កាមែល។ ក្រោយមក នៅឆ្នាំ១៥៦២នៃគ.ស. សន្តីតេរេសា នៃព្រះយេស៊ូ (នៅទីក្រុងអាវីឡា) បានចាប់ផ្តើម ធ្វើការកែទម្រង់ក្រុមឡើងវិញឲ្យដូចទៅនឹងគោលគំនិតដើមរបស់ក្រុមកាមែល។ សព្វថ្ងៃក្រុមកាមែលបព្វជិតាសំងាត់មានសមាជិកចំនួន១០៥០០នាក់ នៅប្រហែលជាជាង៨០០ប្រទេសលើសកលលោក។ នៅប្រទេសកម្ពុជា មានអារាមកាមែលដែលដាក់ឈ្មោះថា "ព្រះមាតាជាទីសង្ឃឹមរបស់យើង" នៅជ្រោយចង្វា ដែលកើតនៅឆ្នាំ១៩១៩។ ប៉ុន្តែ ឆ្នាំ១៩៧៥ ដូនជីសំងាត់កាមែលនោះបាន

ភៀសខ្លួនទៅអារាមមួយនៅប្រទេសបែលស៊ិកដោយសារសង្គ្រាមក្នុងប្រទេសកម្ពុជា ។ចាប់ពីពេលនោះមកអស់រយៈពេល៣០ឆ្នាំ ឥតឃើញដូនជីសំងាត់កាមែលនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០០៥ បព្វជិតា ៥នាក់ មកដល់ស្រុកខ្មែរពីប្រទេសកូរ៉េ ដើម្បីឲ្យកសាងអារាមកាមែលសាជាថ្មីវិញ តាមពាក្យសំណូមពររបស់លោកអភិបាល អេមីល ដេតម្ប។ ឥឡូវនៅអារាមកាមែល នៃព្រះសហគមន៍ភូមិភាគភ្នំពេញ មានសមាជិកចំនួន ៧នាក់។

## សកម្មភាពក្រុម ៖

ស្មិងស្មាធិ៏ អធិដ្ឋានសម្រាប់សកលលោក និង ព្រះសហគមន៍ ធ្វើនំព្រះកាយ ធ្វើអាវវែងសម្រាប់បូជាចារ្យនិងកាត់ដេរគ្រប់មុខសម្រាប់ពិធីបុណ្យផ្សេងៗ ធ្វើទៀន ធ្វើស្រែ ដាំដំណាំគ្រប់កិច្ចការទាំងអស់ដែលអាចធ្វើបានដោយមិនត្រូវការចេញពីអារាម ៕



អធិដ្ឋាន
តាមពេលកំណត់



ច្រូតស្រូវ

# ក្រុមសន្ត ហ្វ្រង់ស៊ីស្កូអាស៊ីស៊ី( ASSISI )

## ប្រវត្តិក្រុម ៖

អ្នកបង្កើតក្រុម គឺសន្តហ្វ្រង់ស៊ីស្កូអាស៊ីស៊ី (ASSISI)។ កើតឆ្នាំ១១៨២ នៅអាស៊ីស៊ី (ASSISI)ប្រទេសអ៊ីតាលីជាកូនក្នុងគ្រួសារអ្នកធ្វើជំនួញធំ។ គាត់ទទួលមរណភាពក្នុងឆ្នាំ ១២២៦ នៅអាយុ៤៤ឆ្នាំ។ ក្រុមបងប្អូនតូចតាចមានវត្តមាននៅប្រទេសកម្ពុជាក្នុងខែសីហា ឆ្នាំ២០១០។ សព្វថ្ងៃចំនួនសមាជិកនៃក្រុមបព្វជិត ហ្វ្រង់ស៊ីស្កូនៅលើពិភពលោកមាន ចំនួន ១៤.០៦៧ នាក់ មានវត្តមានលើ១១០ តាមបណ្តាប្រទេសលើសកលលោក។ បច្ចុប្បន្ន មានសមាជិក៣នាក់ ដែលកំពុងរស់នៅក្នុងប្រទេសខ្មែរ គឺយ៉ូសែបដូឌីករឿង យ៉ូហាន-បាទីស្តដូវទៀងយុង និង អន់តូនីត្រឹងវាំងបៀង។

ឈ្មោះក្រុម៖ ORDO FRATRUM MINORUM ( សរសេរកាត់ OFM )

លក្ខណៈរបស់ក្រុម៖ ប្រតិបត្តិតាមព្រះគម្ពីរ អធិដ្ឋាន ប្រកាសដំណឹងល្អ ប្រកាន់ភាពក្រីក្រ ដាក់ខ្លួន ភាតរភាព បម្រើអ្នកក្រីក្រ ស្រឡាញ់ និងការពារបរិស្ថាន។



## គ្រួសារបព្វជិតនេះចែកជា៣សាខា៖

-សាខាទី១ ៖OFM(cov)
-សាខាទី២ ៖OFM
-សាខាទី៣ ៖OFM(cap)

*សាខានីមួយៗមាន*

ក្រុមបួសទី១ ៖ ក្រុមបងប្អូនតូចតាច(ចំពោះបព្វជិតប្រុស)
ក្រុមបួសទី២ ៖ ក្រុមបួសស្រីសន្តីក្លារ៉ា(សម្ងាត់)
ក្រុមបួសទី៣ ៖ រស់នៅកណ្តាលលោកីយ៍ (រស់តាមស្មារតីសន្តហ្វ្រង់ស៊ីស្កូ នៅកណ្តាលលោកីយ៍) និង រស់នៅក្នុងអារាម(នៅក្នុងក្រុមបួស) អាសយដ្ឋាន ទួលក្រសាំង ស្រុកស្អាង ខេត្តកណ្តាល។

ទូរស័ព្ទបងប្រុសយុង : ០៩៧៥៥៨០៦៧០
បងប្រុសរឿង:០៩៧២៣៦៥០៤៤



## សកម្មភាពក្រុម ៖

សហការជាមួយលោកឪពុកសិលាឡៅវ៉ាន់ទិន ជួយព្រះសហគមន៍ទាំង៤ គឺកោះទៀវ ស្អាង ទួលក្រសាំង និង បឹងឈូក ក្នុងការអប់រំវប្បធម៌អប់រំជំនឿ និង សួរសុខទុក្ខអ្នកក្រីក្រ ៕

# ក្រុមគ្រួសារស្រឡាញ់ព្រះឈើឆ្កាង

## ប្រវត្តិក្រុម ៖

ក្រុមគ្រួសារបព្វជិតាអ្នកស្រឡាញ់ព្រះឈើឆ្កាង ត្រូវបានបង្កើតឡើង ដោយលោកអភិបាលសិលាម៉ារី ឡាំប៊ែរ ដឺឡាម៉ុត ដែលលោកជាសាសនទូតជាតិបារាំង ក្នុងគោលបំណងជួយសហការណ៍ ក្នុងកិច្ចការផ្សាយដំណឹងល្អចំពោះអ្នកកាន់សាសនាដទៃ។ ក្រុមគ្រួសារនេះ គឺស្ថិតនៅក្រោមការដឹកនាំរបស់លោកអភិបាលប្រចាំភូមិភាគ ព្រមទាំងធ្វើការសហការជាមួយបូជាចារ្យតាមព្រះសហគមន៍ដែលខ្លួនកំពុងរស់នៅក្នុងការជួយផ្សព្វផ្សាយដំណឹងល្អ អប់រំជំនឿ ចិញ្ចឹមនិងថែរក្សាកុមារកំព្រា អប់រំស្ត្រី និងបង្រៀនក្នុងសាលារៀន។

នៅប្រទេសកម្ពុជា ក្រុមគ្រួសារបព្វជិតានេះបានកកើតនៅឆ្នាំ ១៧៧២នៃគ.ស. នៅភូមិប្រាំបីឆោម ដោយមានលោក ឡឺវ៉ាវ៉ាសឺ ជាអ្នកទទួលខុសត្រូវក្រុមបព្វជិតានេះ។ ក្នុងឆ្នាំ ១៧៨២ សៀមបានវាយចូលបន្ទាយលង្វែក និងបានបំផ្លាញខ្ទេចខ្ទីដោយសារសង្គ្រាមសម័យនោះ។ តែក្នុងឆ្នាំ១៧៩០ ក្រុមគ្រួសារនេះបានកើតម្តងទៀតនៅខេត្តបាត់ដំបង ហើយនៅឆ្នាំ១៨៤៨ក្រុមគ្រួសារបព្វជិតានេះបានកើតនៅពញាឮដោយមានលោកមីស្សជាអ្នកទទួល



ខុសត្រូវ ហើយនៅឆ្នាំ១៨៦២នៅឫស្សីកែវ ភ្នំពេញ ដោយមានលោកបូស៊ូជាអ្នកទទួលខុសត្រូវ។ នៅឆ្នាំ ១៩៤២ សមាជិកក្រុមគ្រួសារបព្វជិតានេះមានចំនួនសរុប១១៥នាក់។ នៅឆ្នាំ ១៩៩៣ មានបងស្រី២នាក់ មកពីក្រុមគ្រួសារស្រឡាញ់ព្រះឈើឆ្កាង ភូមិភាគអ៊ូប៊ុន ប្រទេសថៃ បានស្ម័គ្រចិត្តមកបម្រើប្រទេសខ្មែរក្នុងភូមិភាគកំពង់ចាម។

នៅឆ្នាំ ១៩៩៨ មានបងស្រីជនជាតិខ្មែរពីរនាក់បានស្ម័គ្រចិត្តចូលទទួលការអប់រំជាជីវិតអ្នកបួសតាមធម្មនុញ្ញនៃក្រុមគ្រួសារស្រឡាញ់ព្រះឈើឆ្កាង។ សព្វថ្ងៃ យើងមានសមាជិកចំនួន ៦នាក់ដែលជាអ្នកបួស និង មានយុវនារី៣រូបកំពុងទទួលការអប់រំទៅជាដូនជីក្នុងក្រុមនេះ។

នៅឆ្នាំ ២០០៧ សមាជិកក្រុមគ្រួសារបងស្រីស្រឡាញ់ព្រះឈើឆ្កាងចូយាន់ពីវៀតណាម ២នាក់បានមកដល់ស្រុកខ្មែរ ហើយ២ឆ្នាំក្រោយមក មានសមាជិកសរុបចំនួន ៤នាក់ទៀតមកបន្ថែម និងបានចូលរួមបម្រើនៅក្នុងភូមិភាគកំពង់ចាម និងភ្នំពេញ ក្នុងនោះនៅភូមិភាគកំពង់ចាមមាន៤នាក់ និង នៅភូមិភាគភ្នំពេញមាន២នាក់។

## សកម្មភាពក្រុម ៖

ការប្រកាសដំណឹងល្អនៅព្រះសហគមន៍ភូមិភាគកំពង់ចាម



សព្វថ្ងៃក្រុមគ្រួសារបព្វជិតនេះកំពុងបំពេញការងារបម្រើតាមព្រះសហគមន៍នានាក្នុងភូមិភាគកំពង់ចាម និងភ្នំពេញ ដោយការអធិដ្ឋាន ជួយអប់រំជំនឿ ចិញ្ចឹមនិងថែរក្សាយុវតីដែលពុំមានលទ្ធភាពក្នុងការទទួលការអប់រំ បង្រៀនក្នុងសាលារៀន និង សួរសុខទុក្ខក្រុមគ្រួសារក្រីក្រតាមភូមិដាច់ស្រយាល៕

# ក្រុមបងស្រីឧបការគុណ

## ប្រវត្តិក្រុម៖



ក្រុមបងស្រី ឧបការគុណ ត្រូវបានបង្កើតនៅតំបន់ឡូរ៉ែនប្រទេសបារាំងនាឆ្នាំ១៧៦២ ដោយលោកបូជាចារ្យម្នាក់ឈ្មោះយ៉ូហានម៉ាតាំងម៉ូយ។ លោកយ៉ូហានម៉ាតាំងម៉ូយ កើតនៅភូមិគូតាំងតំបន់ឡូរ៉ែននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៧៣០។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យថ្ងៃទី ៩ ខែមីនា ឆ្នាំ១៧៥៤។ លោកត្រូវបានចាត់ឲ្យទៅបំពេញបេសកកម្មតាមព្រះវិហារផ្សេងៗនៅទីក្រុងមេត្ស ហើយដោយសារភាពក្រីក្រ ទុរគតភាព អវិជ្ជា របស់ប្រជាជនដែលជំរុញលោកបង្កើតគំរោងការណ៍ផ្ញើនារីទៅគ្រប់ទីកន្លែងដែលគេស្នើសុំដោយគ្មានទុនអ្វីក្រៅពីការពឹងពាក់ទាំងស្រុង ទៅលើព្រះឧបការគុណរបស់ព្រះជាម្ចាស់។ នារីទាំងនេះរស់ក្នុងចំណោមប្រជាជនក្រីក្រ បង្ហាត់បង្រៀនក្មេង អប់រំជំនឿ និងឆ្លើយតបតាមសេចក្ដីត្រូវការរបស់ប្រជាជនក្រីក្រនៅទីនោះ។ ការបន្តផ្ញើក្រុមនារីដូចនេះហើយ ដែលក្រោយមកក្រុមនេះបានក្លាយជាក្រុមបួសបងស្រីឧបការគុណ។ ឆ្នាំ១៧៦៨ លោកម៉ូយបាន ចូលក្រុមសមាគមសាសនាទូតក្រៅប្រទេស( MEP )ហើយថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ១៧៧១ លោកត្រូវបានគេចាត់តាំងឲ្យទៅប្រទេសចិន។ ក្រោមការស្នើសុំរបស់លោកអភិបាលក័រឌីយេប្រចាំនៅប្រទេសកម្ពុជា នៅឆ្នាំ១៨៧៥ បងស្រីឧបការគុណ៦នាក់បានធ្វើដំណើរមកជ្រោយឥណ្ឌូចិន ហើយបានតាំងទីលំនៅនៅគូឡាវយោងជាទីស្នាក់ការរបស់លោកអភិបាលសម័យ

នោះ។ ឆ្នាំ១៨៨០ បងស្រីបានបើកសាលាបំប៉ួសនារីក្នុងស្រុក។ ឆ្នាំ១៨៨១ បងស្រី២នាក់បានឡើងមកតាំងទីលំនៅនៅភ្នំពេញ។ នៅទីនេះបងស្រីបានបង្កើត ទារកដ្ឋាន មណ្ឌលចិញ្ចឹមក្មេងកំព្រា មណ្ឌលទទួលចាស់ទុំគ្មានទីពឹង និងសាលារៀនដែល មានឈ្មោះថា ប្រូវីដង្ស។ ឆ្នាំ១៩០៥បងស្រីបានពង្រីកកម្មវិធីទៅដល់ខេត្តបាត់ដំបង។ឆ្នាំ១៩៤៥-៤៦ ផ្ទះរបស់បងស្រីនៅគូឡាវយាងត្រូវបានបំផ្លាញដោយពួកវៀតមិញ។បងស្រីទាំងអស់បានចាកចេញពីទីនោះមករស់នៅភ្នំពេញវិញ។ ចាប់ពីពេលនោះ រហូតដល់ ឆ្នាំ១៩៥៩ ផ្ទះនៅភ្នំពេញបានក្លាយជាផ្ទះដើមរបស់បងស្រីឧបការគុណនៅជ្រោយឥណ្ឌូចិនវិញ។ ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានទទួលឯករាជ្យពីបារាំង។ ឆ្នាំ១៩៥៥ សម្តេចប៉ាប បានផ្តាច់ខេត្តដែនកូសាំងស៊ីន ចេញពីការគ្រប់គ្រងរបស់លោកអភិបាលព្រះសហគមន៍កម្ពុជា ហើយបានបង្កើតភូមិភាគកឹងចឺ។ បងស្រីឧបការគុណបានចែកផ្ទះដើមរបស់ខ្លួនជាពីរកន្លែង គឺមួយនៅភ្នំពេញនិងមួយនៅកឹងចឺ។ថ្ងៃទី១៧មេសា១៩៧៥បងស្រីឧបការគុណត្រូវបានជម្លៀសចេញពីផ្ទះដូចប្រជាពលរដ្ឋឯទៀតៗដែរ។ បងស្រី៦នាក់ត្រូវបាត់បង់ជីវិតក្រោមរបបប៉ុលពត។ បងស្រីមួយចំនួនបានទៅដល់វៀតណាមចុងខែវិច្ឆិកា ឆ្នាំ១៩៧៥។ ចាប់តាំងពីឆ្នាំ១៩៧៦-១៩៩១ បងស្រីឧបការគុណក៏អវត្តមានពីប្រទេសកម្ពុជា។ ថ្ងៃទី១១-១៣ ខែមករា ឆ្នាំ ១៩៩១ បងស្រី៤នាក់បានត្រឡប់មកប្រទេសកម្ពុជាវិញ។

## សកម្មភាពក្រុម ៖

ក្រុមបងស្រីមានវត្តមាននៅភូមិភាគបាត់ដំបង និងភ្នំពេញដោយសហការជាមួយបូជាចារ្យ និង អ្នកទទួលខុសត្រូវព្រះសហគមន៍ផ្សេងៗ ជួយអប់រំជំនឿ ណែនាំក្រុមចម្រៀងជួយណែនាំក្រុមត្រាស់ហៅសម្រាប់យុវតី ជួយជ្រោមជ្រែងជនពិការ ចាស់ជរា អ្នកជំងឺ ទទួលខុសត្រូវមណ្ឌលសម្រាប់ក្មេងគរថ្លង់និងងងឹតភ្នែក ដោយផ្តល់ឱកាសឲ្យគេបានទទួលការអប់រំត្រឹមត្រូវ ជួយពង្រឹងស្មារតីយុវជន យុវនារីឲ្យចេះរស់នៅប្រកបដោយធន្ទៈ និងស្មារតីរួបរួម និង ជួយបណ្តុះបណ្តាលមាតាបិតាឲ្យចេះយកចិត្តទុកដាក់ណែនាំ និងជម្រុញបុត្រធីតារបស់ខ្លួន៕



# ក្រុមគ្រួសារបងស្រីព្រះមាលា

## ប្រវត្តិក្រុម៖

ក្រុមគ្រួសារបងស្រី "ព្រះមាលា" កើតឡើងនៅប្រទេសបារាំង ដោយបងស្រី ហ្សឺរ៉ូអេលីសាប៉ែត។ បងស្រីអេលីសាប៉ែត កើតនៅក្នុងគ្រួសារមួយក្នុងចំណោមគ្រួសារក្រីក្រឯទៀតក្នុងភូមិនាសម័យនោះ។ ក្រោយពេលដែលឪពុករបស់គាត់ទទួលមរណភាពទៅ គ្រួសាររបស់បងស្រីបានធ្លាក់ក្នុងស្ថានភាពក្រីក្រយ៉ាងខ្លាំង។ ពេលនោះបងស្រីអេលីសាប៉ែតបានទៅស៊ីឈ្នួលធ្វើការឲ្យគេនៅឯចម្ការដើម្បីចិញ្ចឹមម្ដាយដែលមានជំងឺវង្វេងស្មារតី និង ប្អូន



ប្រុសតូចម្នាក់។ បងស្រីអេលីសាប៉ែតមានជំនឿយ៉ាងមាំលើព្រះជាម្ចាស់និងគាត់មានចិត្តស្រឡាញ់អ្នកដទៃយ៉ាងខ្លាំង។ គាត់បានទទួលមនុស្សចាស់ជរាម្នាក់ឲ្យស្នាក់នៅជាមួយគាត់ ហើយគាត់ក៏យកចិត្តដាក់សួរសុខទុក្ខអ្នកជំងឺ និង ក៏ខិតខំបង្ហាត់បង្រៀនកូនក្មេងក្រីក្រដែលមិនមានលទ្ធភាពទៅសាលារៀនដែរ។ យុវនារីក្នុងភូមិមួយចំនួនចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះចិត្តស្រឡាញ់និងចិត្តសប្បុរសរបស់បងស្រីចំពោះអ្នកដទៃហើយពួកគេបានមកសុំរស់នៅជាមួយបងស្រី។ដូច្នេះហើយក្រុមបងស្រី "ព្រះមាលា" ក៏បានបង្កើតឡើងនៅក្នុងឆ្នាំ ១៨៣២។ សព្វថ្ងៃនេះក្រុមបងស្រីព្រះមាលាបានបន្តបេសកកម្មរបស់បងស្រីហ្សីរ៉ូអេលីសាប៉ែតនៅឯប្រទេសបារាំង ទ្វីបអាហ្វ្រិក និងប្រទេសកម្ពុជាដែរ។ នៅប្រទេសកម្ពុជាមានក្រុមគ្រួសារបងស្រី "ព្រះមាលា" មួយក្រុមនៅភ្នំពេញថ្មីដែលមានបងស្រីចំនួន ៣នាក់ និងណូវីសម្នាក់គឺ ៖បងស្រីស៊្សីប៉ែត បងស្រីអានម៉ារី បងស្រីម៉ារីវី និង កញ្ញាឃឹម សុខា។



## សកម្មភាពក្រុម ៖

១- បងស្រីស៊្សីប៉ែត ៖ធ្វើការនៅមណ្ឌលអប់រំជំនឿកាតូលិកកម្ពុជាជាអ្នករៀបចំឯកសារផ្សេងៗព្រមទាំងជួយណែនាំអ្នកអប់រំជំនឿតាមព្រះសហគមន៍ផង។

២- បងស្រីអានម៉ារី៖ចុះទៅតាមជនបទដើម្បីជួយគ្រួសារក្រីក្រដូចជាជួយឧបត្ថម្ភកូនសិស្សក្រីក្រ ឲ្យបានទៅសាលារៀន ព្រមទាំងជួយព្យាបាលអ្នកជំងឺតាមរយៈអង្គការពន្លកថ្មី។

៣- បងស្រីម៉ារីវី ៖ កំពុងសិក្សានៅមហាវិទ្យាល័យពេទ្យផ្នែកគិលានុបដ្ឋាកយិកា។

៤- កញ្ញាឃឹម សុខា ៖ កំពុងទទួលការអប់រំទៅជាបងស្រីក្នុងឆ្នាំទី១ (ណូវីស) ។

ក្រៅពីនេះ ក្រុមបងស្រីព្រះមាលា មានមណ្ឌលសម្រាប់ទទួលយុវនារីមកពីគ្រួសារក្រីក្រដើម្បីបន្តរៀននៅវិទ្យាល័យ និង ទទួលបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្សេងៗ៕

# ក្រុមគ្រួសារអ្នកបម្រើបេះដូង
# ដ៏និមលរបស់ព្រះនាងម៉ារី





## ប្រវត្តិក្រុម ៖

នៅឆ្នាំ១៩៩៧ បងស្រីក្រុមអ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី បានចូលមកប្រទេសកម្ពុជា ហើយបានបោះទីតាំងនៅខេត្តកំពង់ធំ។ សព្វថ្ងៃមានសមាជិកចំនួន ៥នាក់ ជាជនជាតិថៃ ៤ នាក់ និង ជនជាតិខ្មែរ១នាក់។

*ទស្សនវិស័យក្រុម* ៖ បងស្រីអ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី ជាគ្រីស្តទូតដែលមានជីវិតឧទ្ទិសខ្លួនបំរើព្រះសហគមន៍ ជាសាក្សីនៃសេចក្តីស្រលាញ់របស់ព្រះគ្រីស្តមានជីវិតសុភាពរាបសា មានឯកភាពនៃគ្រួសារ ព្រមជានិច្ចក្នុងការធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ដូចព្រះនាងម៉ារី។

*ស្មារតីក្រុម៖* ស្មារតីរបស់គ្រួសារគឺ ស្រលាញ់ បម្រើ លើកលែងទោស ព្រមជានិច្ចក្នុងការឆ្លើយតបថា"នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់" ដូចព្រះនាងម៉ារី ដោយឧទ្ទិសជីវិតក្នុងការបម្រើព្រះជាម្ចាស់ក្នុងបងប្អូនទាំងអស់ ព្រមធ្វើអ្វីៗគ្រប់បែបយ៉ាងដែលជាព្រះហឫទ័យរបស់ព្រះអង្គដោយមានចិត្តលះបង់ ទោះបីក្នុងករណីពិបាកក៏ដោយ ព្រោះក្តីស្រលាញ់ចំពោះព្រះគ្រីស្ត។

*បាវចនាក្រុម៖* "សេចក្តីស្រលាញ់របស់ព្រះគ្រីស្តជំរុញយើង" (២ គរ៥:១៤)

## សកម្មភាពក្រុម ៖

ឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ព្រះសហគមន៍ភូមិភាគ រួមការងារក្នុងកិច្ចការផ្សេងៗរបស់ព្រះសហគមន៍ ដូចជាការអប់រំជំនឿ ការអប់រំសិក្សានៅសាលារៀន ការងារផ្ទះ និងការងារមេត្តាករុណា ពិសេសចំពោះអ្នកដែលត្រូវការការជួយធុរៈទាំងកាយទាំងផ្លូវចិត្ត។

ឆ្នាំ ១៩៩៧ បានចាប់ផ្តើមបំពេញបេសកកម្មនៅខេត្តកំពង់ធំ ដោយទទួលខុសត្រូវលើការអប់រំជំនឿ សាលាមត្តេយ្យ មណ្ឌលសិស្ស និង សិប្បកម្មកាត់ដេរ។

ឆ្នាំ ២០១២ បានចាប់ផ្តើមបំពេញបេសកកម្មនៅ ខេត្តសៀមរាប ដោយទទួលខុសត្រូវការអប់រំជំនឿតាមភូមិ មណ្ឌលអប់រំកុមារ និង មណ្ឌលនិស្សិតសកលវិទ្យាល័យ៕



# ក្រុមគ្រួសារបងស្រី
# នៃលិទ្ធិគ្រីស្តសាសនា

## ប្រវត្តិក្រុមៈ



ប្រទេសអាឡឺម៉ង់ និង ប្រទេសបារាំងជាប្រទេស(ខេត្តរ៉ូរិន)ដែលមានព្រំដែនជាប់គ្នា។ នៅក្នុងអំឡុងសតវត្សទី១៧ប្រទេសទាំងពីរបានមានជម្លោះព្រំដែនរវាងគ្នា និង គ្នារហូតមានការប្រើអាវុធបាញ់តតាំងគ្នាទៅវិញទៅមក។ ឥទ្ធិពលនៃសង្គ្រាមបានធ្វើឲ្យប្រជាពលរដ្ឋនៃប្រទេសទាំងពីរទទួលរងនូវវិបត្តិផ្សេងៗមាន ស្លាប់មនុស្ស បាក់បែកផ្ទះសំបែង សាលារៀន មនុស្សព្រាត់ប្រាសគ្រួសារ មានមនុស្សពិការ កុមារកំព្រានិងមានបញ្ហាផ្សេងៗជាច្រើនទៀត។ ដោយមើលឃើញសភាពជាក់ស្តែងទាំងអស់នោះ លោកឪពុកជនជាតិបារាំងម្នាក់ ឈ្មោះ យ៉ូហាន បាទីស្តមានគរុកោសល្យអប់រំខាងផ្លូវវិញ្ញាណ និង អ្នកមានវិបត្តិផ្លូវចិត្ត។ លោកឪពុករូបនេះមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអ្នករងឥទ្ធិពលទាំងនោះ ជាពិសេសលោកផ្តោតអារម្មណ៍លើក្មេងស្រីៗ ។

ជាបឋម លោកចាប់ផ្តើមធ្វើការជួយប្អូនស្រីបីនាក់នៅតាមភូមិ ដោយមានគរុកោសល្យ

យ៉ាងប៊ិនប្រសប់ប្រកបដោយមេត្តាករុណាផងនោះមិនយូរប៉ុន្មានកុមារីទាំងបីរូបក៏បានជាសះស្បើយពីស្នាមរបួសផ្លូវចិត្ត ពួកនាងមានជីវិតពេញបរិបូរណ៍ មានជំនឿតែមួយក្នុងការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់ និង បានជាមនុស្សពេញវ័យខាងជំនឿលើព្រះគ្រីស្ដដែលបំពេញអ្វីៗទាំងអស់។ ពួកនាងចង់ក្លាយជាអ្នកបួស និង បានរួមគ្នាបម្រើព្រះជាម្ចាស់គឺបម្រើបងប្អូនតាមអំណោយទានដែលបានមកពីព្រះជាម្ចាស់។ ដោយសារអំណោយទាននេះ ពួកនាងត្រូវបានបញ្ជូនឲ្យទៅអប់រំតាមសាលា តាមភូមិនានាជាបន្តបន្ទាប់។ លោកឪពុក យ៉ូហាន បាទីស្ត តែងតែដកស្រង់អត្ថបទគម្ពីរយកមកទូន្មានប្រៀនប្រដៅដល់បងប្អូនជំនាន់នោះ ជាពិសេស អប់រំយុវនារីទាំងឡាយដែលបានក្លាយជាគ្រឹះយ៉ាងរឹងមាំខាងព្រលឹងវិញ្ញាណ។ បន្ទាប់មកបានរីករាលដាល រហូតបានប្រហែល១០ប្រទេសមកដល់សព្វថ្ងៃដែលដំបូងផ្ដើមពីប្រទេសបារាំង ប្រទេសបែលហ្ស៊ិក ប្រទេសលុចសំបួរ ប្រទេសឈីលីប្រទេស កូដឺវ៉រ ប្រទេសអាល់សេរី ប្រទេសកុងហ្គូ ប្រទេសកូរ៉េ និង ប្រទេសកម្ពុជា។ រីឯប្រទេសកម្ពុជា នៅឆ្នាំ២០១០មានបងស្រីបីនាក់បានអញ្ជើញមកជាដំបូង។ ដើម្បីសម្រួលដល់សកម្មភាពការងារផ្សេងៗដែលនឹងត្រូវបំពេញ ពួកគាត់បានស្នាក់នៅរាជធានីភ្នំពេញរយៈពេលមួយឆ្នាំដើម្បីរៀនភាសាខ្មែរ។ ឆ្នាំទីពីរ គឺឆ្នាំ២០១១បងស្រីបានអញ្ជើញមកព្រះសហគមន៍ភូមិភាគបាត់ដំបង ដោយរៀនភាសាខ្មែរបណ្ដើរ និងធ្វើការបណ្ដើររហូតដល់ឆ្នាំ២០១២ ក្រុមបងស្រីបានសម្រេចចិត្តមកបំរើការក្នុងព្រះសហគមន៍ពោធិ៍សាត់។

## សកម្មភាពក្រុម ៖

កិច្ចការដែលក្រុមយើងកំពុងផ្ដោតជាសំខាន់ គឺការចុះសួរសុខទុក្ខគ្រីស្ដបរិស័ទ ដោយអប់រំគេអំពីការថែរក្សាសុខភាព ការបង្កើត និង ណែនាំមជ្ឈមណ្ឌលសន្ដីហាណា បណ្ណាល័យចល័តដោយមួយសប្ដាហ៍ចំណាយពេលប្រាំថ្ងៃ យកសៀវភៅទៅតាមសាលាបឋមសិក្សាជនបទឲ្យសិស្សអាន បង្រៀនភាសាអង់គ្លេស មើលវីដេអូអប់រំ បំពេញសកម្មភាពផ្សេងៗមានផាត់ពណ៌ជាដើម ជួយការងារព្រះវិហារ អប់រំជំនឿ បង្ហាត់ភ្លេង បង្ហាត់ចម្រៀងកោតសសើរព្រះជាម្ចាស់ កសាងសាលាមត្តេយ្យ និង ជួយគ្រួសារក្រីក្រ៕




# ក្រុមជូនដីនៃក្រុមគ្រួសារព្រះកុមារ យេស៊ូ ពីស្វហ្វេយ៍



## ប្រវត្តិក្រុម៖

វាត្រូវចំណាយរយៈពេលអស់ប្រហែល ១៥០ឆ្នាំ ដែលព្រះជាម្ចាស់បានជ្រើសរើស Reine Antier ដែលមានអាយុ ៥៨ឆ្នាំ ដើម្បីឲ្យបង្កើតក្រុមជូនដី នៃក្រុមគ្រួសារព្រះកុមារយេស៊ូពីសូហ្វៃយ៍។ សម្រាប់បងស្រី Reine Antier គម្រោងការណ៍នេះពុំដែលមានក្នុងគំនិតគាត់សោះ។ បងស្រីត្រូវប្រឈមមុខច្រើនក្នុងការណែនាំក្រុមក្នុងក្តីមន្ទិល ក្នុងភាពងងឹតក្នុងសេចក្តីលំបាកគ្រប់បែបយ៉ាងដោយគេពុំទទួលស្គាល់។ បងស្រីតែងតែទូលអង្វរឥតឈប់ឈរទៅកាន់ព្រះជាម្ចាស់ថា៖"តើព្រះអង្គចង់បានអ្វីពីទូលបង្គំ?"វាពិតជាងងឹតងងុលណាស់សម្រាប់គាត់។ បើអីចឹង តើព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះគាត់ និង ក្រុមទាំងមូលគឺអ្វីទៅ? បងស្រី Reine Antier រស់នៅក្នុងវិថីដ៏ពោរពេញដោយភាពមន្ទិលនេះដោយឆ្លងកាត់ការអធិដ្ឋានប្រកបដោយជំនឿ។ ក្នុងពេលមួយដែលគាត់ខិតខំស្វែងរកព្រះហឫទ័យរបស់ទ្រង់ ស្រាប់តែគាត់បានមើលឃើញពន្លឺនៃក្តីសង្ឃឹម។ គាត់បានទៅជួបជាមួយនឹងសន្ត យ៉ូហាន ម៉ារីយ៉ាណៃ ដើម្បីសុំសួរយោបល់ ប៉ុន្តែអ្វីដែលសន្តនេះគាត់បានឲ្យ

យោបល់គឺ៖ "ព្រះអង្គសព្វព្រះទ័យអោយអ្នកទៅ Chauffailles"។ បងស្រីក៏ទទួលយកវា ដោយជំនឿតាមរយៈឧទាហរណ៍ដ៏ប្រសើររបស់ព្រះនាងម៉ារី ដែលព្រះនាង បានរស់នៅ ដោយស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយក៏ឆ្លើយ៖ "ចាស៎!" ជានិច្ចដោយពុំមានលក្ខខណ្ឌ។ ម៉្យាងទៀតបងស្រី ក៏មានជំនឿលើបងស្រីឯទៀតៗក្នុងក្រុមដែលមានសេរីភាពក្នុងការជ្រើស រើសរស់នៅ Chauffailles ឬក៏ត្រឡប់ទៅ Puy។ តាមពិតក្តីស្រឡាញ់ដែលកើតចេញពីការ ប្រមើលមើលការអស្ចារ្យ នៃកំណើតរបស់ព្រះអម្ចាស់តែងតែជម្រុញឲ្យមនុស្សម្នាក់ៗលះ បង់អ្វីៗទាំងអស់ដើម្បីព្រះជាម្ចាស់ដែលជាព្រះប្រកបដោយឫទ្ធានុភាពសព្វប្រការ គឺគ្មាន អ្វីដែលធ្វើពុំបានឡើយសម្រាប់ទ្រង់។ ដូច្នេះក្រុមនេះត្រូវបានបង្កើតនៅ Chauffailles ប្រទេសបារាំងនៅឆ្នាំ ១៨៥៩។



## សកម្មភាពក្រុម ៖

### *ខេត្តកំពត និង តាកែវ*

បងស្រីHASHIMOTO SHINKO ជាអ្នកគ្រប់គ្រងគម្រោងថ្នាក់រៀនANTIER និង កម្មវិធី អានសៀវភៅសម្រាប់កុមារក្នុងខេត្តកំពត និង តាកែវដោយបង្កើតបណ្ណាល័យមួយនៅ FLCCក្នុងខេត្តកំពត និង បន្ទប់អានសៀវភៅក្នុងភូមិចំនួន ៥ ផ្សេងទៀត។ ថ្នាក់ ANTIER ក្នុងភូមិចំនួន ៥ មានបង្រៀនសន្ទនាភាសាអង់គ្លេសងាយៗ និង ការអានសៀវភៅរួមគ្នា ម្តងក្នុង១សប្តាហ៍។

បងស្រី SONODA KUNIKO ជាអ្នកសម្របសម្រួលសាលាមត្តេយ្យអប់រំMONTESSORI នៅសាលាមត្តេយ្យព្រះកុមារយេស៊ូរបស់ព្រះសហគមន៍សន្តីតេរេសា នៃព្រះកុមារយេស៊ូក្នុង ខេត្តតាកែវ។

### *ខេត្តសៀមរាប*

បងស្រី KUROIWA ATSUKO ជានាយិការបស់សាលាមត្តេយ្យANTIER។

បងស្រី KASHINO SUMIKO ជាអ្នកបម្រើការងារក្នុងព្រះវិហារមួយចំនួន។

# បងប្រុសគោរពព្រះនាងម៉ារី

## ប្រវត្តិសង្ខេប៖

នៅថ្ងៃទី២ ខែមករា ឆ្នាំ១៨១៧ លោកម៉ាសេឡង់ ចំប៉ាញ៉ាត (marcellin Champagnat) បង្កើតក្រុមគ្រួសារបងប្រុសតូចនៃព្រះនាងម៉ារីដែលជាក្រុមគ្រហស្ថ ឬជាក្រុមគ្រួសារបងប្រុសបព្វជិតនៅឡាវ៉ាឡា នៅប្រទេសបារាំង។

នៅឆ្នាំ ១៨៦៣ សន្តអាសនៈបានអនុម័តទទួលស្គាល់យើង ជាគ្រឹះស្ថានឯករាជ្យរបស់សម្តេចប៉ាប (Pontifical Right)។ ខណៈពេលទទួលស្គាល់នោះ ពួកយើងត្រូវបានផ្តល់ឈ្មោះថ្មីថា សាលានៃបងប្រុសគោរពព្រះនាងម៉ារី( Marist Brothers of the Schools (English) /F.M.S-Fratres Maristae a Scholis)។ ក្រុមបងប្រុសគោរពព្រះនាងម៉ារីបានមកដល់ប្រទេសកម្ពុជាកាលពី១២ឆ្នាំមុន ក្នុងអំឡុងឆ្នាំ២០០២។ គឺមានបងប្រុសចំនួនពីរនាក់ ជាជនជាតិអូស្ត្រាលី បានបង្កើតសាលារៀនឡាវ៉ាឡា។ បច្ចុប្បន្ននេះ យើងមានបងប្រុសចំនួន១០នាក់រស់នៅក្នុងប្រទេសកម្ពុជា គឺ ២នាក់នៅសែនមនោរម្យ (ខេត្តមណ្ឌល គិរី) ២នាក់ទៀតនៅភ្នំពេញកំពុងសិក្សាភាសាខ្មែរ ២នាក់ទៀតនៅតាខ្មៅកំពុងមើលការខុសត្រូវសាលាឡាវ៉ាឡា និង៤នាក់ទៀតនៅប៉ៃលិន។ ក្រៅពីនោះយើងក៏មានអ្នកស្ម័គ្រចិត្តមកពីម៉ិកស៊ិកូចំនួន២នាក់ ដែលកំពុងធ្វើការនៅប៉ៃលិន។



## សកម្មភាព ៖

នៅក្នុងប្រទេសកម្ពុជា ក្រុមបងប្រុសគោរពព្រះនាងម៉ារី និង ក្រុមគ្រហស្ថដែលជាដៃគូកំពុងធ្វើការនៅ៣ទីកន្លែង គឺក្រុងតាខ្មៅក្នុងខេត្តកណ្តាល ខេត្តប៉ៃលិន និងនៅក្រុងសែនមនោរម្យក្នុងខេត្តមណ្ឌលគិរី៕




- **នៅតាខ្មៅ ៖** យើងមានសាលាឡាវ៉ាឡា សម្រាប់ទទួលសិស្សពិការ

- **នៅប៉ៃលិន ៖** យើងទទួលខុសត្រូវមណ្ឌលសកម្មភាពនៃព្រះសហគមន៍កាតូលិក។ យើងបានជួលផ្ទះសម្រាប់បង្រៀនកុំព្យូទ័រ ភាសាអង់គ្លេស និង បើកជាបណ្ណាល័យសិក្សាសម្រាប់សិស្សានុសិស្ស។

- **នៅសែនមនោរម្យ ៖** យើងសហការជាមួយព្រះសហគមន៍ភូមិភាគកំពង់ចាម និងយើងទទួលខុសត្រូវមណ្ឌលស្នាក់នៅសម្រាប់សិស្សជនជាតិភាគតិច។

# បុត្រីនៃមេត្តាករុណា សន្តវ៉ាំងសង់ ដឺប៉ូល



**ប្រវត្តិសង្ខេប ៖**

"ព្រះហឫទ័យមេត្តាករុណាបាននាំពួកគេមកជួបជុំគ្នា ដើម្បីឃើញនូវភាពទុគ៌តនៃជំនាន់របស់គេ៖ អ្នកស្រេកឃ្លាន អ្នកជំងឺ អ្នកត្រូវគេបោះបង់ចោល អ្នកគ្មានការអប់រំ អ្នកធ្វើការហួសកម្លាំង អ្នកមិនទទួលបានការគាំពារ និងអ្នកត្រូវបានគេរំលោភបំពានជាដើម..."

ម៉ាហ្គើរេត ណាសេអូ (Marguerite Naseau)ជូនជីដំបូង ដែលមានឆន្ទៈបម្រើអ្នកក្រីក្រ និងបង្ហាញផ្លូវទៅរកសុភមង្គលដល់បងប្អូនឯទៀត។ ដោយមានការបំភ្លឺពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ បងស្រីបានបូជាកាយក្នុងការបម្រើអ្នកដទៃ ដែលភាគច្រើនគឺអស់អ្នកដែលគេបោះបង់ចោល រហូតទទួលមរណភាពដោយសារឆ្លងជំងឺប៉េស្ត ពីក្មេងស្រីកើតជំងឺនេះដែលបានគេងរួមគ្រែជាមួយនឹងគាត់។ គំរូរបស់បងស្រីបានធ្វើឲ្យមនុស្សជាច្រើនដើរតាមមាគ៌ានេះកាន់តែច្រើនឡើងៗគឺក្នុងមាគ៌ានៃព្រះឧបការគុណដែលសហគមន៍ស្ត្រីបានចាប់បដិសន្ធិឡើងជា *បុត្រីនៃមេត្តាករុណាវ៉ាំងសង់ ដឺប៉ូល* ។



ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ១៦៣៣៖ ស្ថាបនិកក្រុមបុត្រីមេត្តាករុណា លូវីស ដឺម៉ារីលឡាក(Louise de Marillac) បានប្រមូលយុវស្ត្រីដោយណែនាំឲ្យរស់នៅរួមគ្នាជាសហគមន៍។ បងស្រី លូវីស (Luise) និងវ៉ាំងសង់ (Vicent) ហ៊ានចាត់បុត្រីនៃមេត្តាករុណាឲ្យដើរមើលតាមដងវិថីនានាក្នុងប្រទេសបារាំងក្រែងជួបអ្នកក្រីក្រ។ ក្រុមនេះមានបាវចនា៖ "មេត្តាករុណា នៃព្រះគ្រីស្ត ជាប់លើឈើឆ្កាងជំរុញយើង! "

ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៨៦២៖ ក្រុមនេះមកដល់ប្រទេសភីលីពីន។ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ១៩៦៩បានចាប់ផ្តើមបេសកកម្មនៅប្រទេសថៃគឺមានបងស្រីពីរនាក់ពីប្រទេសភីលីពីន និងបងស្រីពីរនាក់ទៀតពីសហរដ្ឋអាមេរិក ដើម្បីថែទាំអ្នកជំងឺឃ្លង់។ ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៩ ពង្រីកបេសកកម្មដល់ប្រទេសឡាវ និងកម្ពុជា។

បច្ចុប្បន្ននេះ បុត្រីមេត្តាករុណាកម្ពុជាស្ថិតនៅក្នុងសហគមន៍បី គឺក្រុងប៉ៃលិន រាជធានីភ្នំពេញ និងក្រុងដូនកែវ(ខេត្តតាកែវ)មានបងស្រីបីនាក់នៅតាមសហគមន៍នីមួយៗ។

## សកម្មភាព៖

### *សហគមន៍ក្នុងខេត្តតាកែវ៖*

១- សុខភាពសហគមន៍ និងផ្តល់អាហារូបត្ថម្ភ
២- ជួយអប់រំកុមារ និងយុវជន
៣- កម្មវិធីប្រាក់សន្សំជួយខ្លួនឯង
៤- លើកកម្ពស់សុខភាពផ្លូវចិត្ត
៥- ការពារការជួញដូរមនុស្ស
៦- កម្មវិធីស្តីពីចំណាកស្រុកដោយសុវត្ថិភាព។

### *សហគមន៍ក្នុងក្រុងប៉ៃលិន៖*

១- មណ្ឌលថែទាំកុមារ (អាយុ ៣-៨ឆ្នាំ)
២- ជួយអប់រំកុមារ និងយុវជន
៣- កម្មវិធីស្តីពីចំណាកស្រុកដោយសុវត្ថិភាព។

### *សហគមន៍ក្នុងក្រុងភ្នំពេញ៖*

១- មណ្ឌលលីនដាវ៉ា (Lindalva) សម្រាប់ស្ត្រី កុមារ និងក្រុមគ្រួសាររបស់គេ (ផ្តោតលើស្ត្រី និងក្រុមគ្រួសារកម្មការិនីរោងចក្រ ការដ្ឋានសំណង់ អ្នកដើរលក់តាមចិញ្ចើមផ្លូវ និងអ្នករើសអេតចាយ )

ក. មណ្ឌលថែទាំកុមារ

 

ខ. ថ្នាក់បំប៉នកុមារសម្រាប់កុមារគ្រប់អាយុចូលរៀន

គ. ថ្នាក់អក្ខរកម្មសម្រាប់កុមារបោះបង់សាលា

ឃ. ថ្នាក់មូលដ្ឋានគ្រឹះកុំព្យូទ័រសម្រាប់កុមារ និងស្ត្រី

ង. ការបណ្តុះបណ្តាល និងអប់រំសម្រាប់ស្ត្រី និងមាតាបិតា។

២- កម្មវិធីនៅបឹងត្របែកសម្រាប់គ្រួសារចំណាកស្រុកពីជនបទ (ផ្តល់សេវាស្នាក់នៅបណ្តោះអាសន្នសម្រាប់គ្រួសារពួកគេនៅបឹងត្របែក ថ្នាក់ចល័តសម្រាប់កុមារ សេវាថែទាំសុខភាពដល់កុមារនិងក្រុមគ្រួសារ ជួយអប់រំដល់កុមារនិងយុវជន)។

៣- ការបញ្ចូលបន្ថែម៖ កម្មវិធីសុខភាពភូមិភាគ (កំដរអ្នកជំងឺ និងក្រុមគ្រួសាររបស់គេដែលស្នាក់នៅមណ្ឌលថែរក្សាជំងឺសន្តិអេលីហ្សាបិត និង មណ្ឌលសុខភាពសន្តលូកា)៕



# ក្រុមបងស្រីគង្វាលដ៏សប្បុរស

## ប្រវត្តិសង្ខេប ៖

ក្រុមបព្វជិតាគង្វាលដ៏សប្បុរស (Congregation of our Lady of Charity of Good Shepherd) បង្កើតឡើងដោយបងស្រី Mary Euphrasia Pelletier ក្នុងឆ្នាំ១៨៣៥ នៅប្រទេសបារាំង។ ក្រុមនេះស្ថិតក្រោមគ្រឹះស្ថានសម្តេចប៉ាប សម្រាប់បព្វជិតាអន្តរជាតិ។ ក្នុងឋានៈជាក្រុម បព្វជិតាដោយទទួលបានការត្រាស់ហៅឲ្យបំពេញបេសកកម្មសម្រាប់ការផ្សះផ្សារ យើងចង់បង្ហាញព្រះអំណោយទាននៃសេចក្តីស្រឡាញ់ដោយចិត្តមេត្តារបស់យើង តាមរយៈជីវិតជាគ្រីស្តទូត និង ជីវិតសញ្ជឹងគិតពីព្រះជាម្ចាស់។





**បាវចនានៃយើង ៖** *"មនុស្សម្នាក់មានតម្លៃខ្លាំងជាងពិភពលោកទាំងមូល"*។

ក្រុមរបស់យើង មានវត្តមាននៅក្នុងប្រទេសជាង៧០ ក្នុងទ្វីបទាំង៥។ ក្រុមបព្វជិតាគង្វាលដ៏សប្បុរសនេះ បានមកដល់ប្រទេសកម្ពុជានៅឆ្នាំ ២០០៦។

បច្ចុប្បន្ននេះ យើងមានគ្នាចំនួន ៤ នាក់ ក្នុងសហគមន៍៖

- *បងស្រី Michelle Lopez*
- *បងស្រី Noela Mendis*
- *បងស្រី Prantiati*
- *បងស្រី Kevin Yin*

## សកម្មភាព ៖

បច្ចុប្បននេះ យើងកំពុងធ្វើការនៅក្នុងខេត្តព្រះសីហនុប៉ុណ្ណោះ ជាមួយស្ត្រីក្មេងស្រី ដែលគេចាត់ទុកមិនសំខាន់



និងកុមារក្រីក្រ។ ភាគច្រើនយើងជួបពួកគេនៅតាមបានីយដ្ឋាន ក្នុងពន្ធនាគារ ឬ តាមភូមិដាច់ស្រយាល។ យើងកំពុងផ្តល់ឲ្យពួកគេនូវជំនាញកាត់ដេរ ផ្នែកកែសម្ផស្ស និងសិប្បកម្ម។ ក្រៅពីសកម្មភាពទាំងនេះ យើងក៏ជួយអប់រំពួកគេដោយផ្តល់ឱកាសឲ្យពួកគេរៀនភាសាអង់គ្លេស ភាសាខ្មែរ ក្រមសីលធម៌ អនាម័យ ការការពារខ្លួនឯង និងផ្តល់ការប្រឹក្សាយោបល់ខ្លះដល់ពួកគេ៕

# The Little Daughters of Our Mother of Inclusive Love

## ប្រវត្តិសង្ខេប ៖

ជាការឆ្លើយតបទៅនឹងស្ថានភាពលំបាកនៃអ្នកក្រីក្រនៅព្រះសហគមន៍ភូមិភាគបាត់ដំបង លោកអភិបាល ហ្វីការដូ អេនរីគេបានបង្កើតក្រុមជឿស៊ប់នេះ " The Little Daughters of Our Mother of Inclusive Love" នៅឆ្នាំ២០០៧ ក្នុងបេសកកម្មច្បាស់លាស់ ដើម្បីបម្រើសេចក្តីត្រូវការអ្នកក្រីក្រ អ្នកជំងឺ ក្មេងកំព្រា និងអ្នកខ្វះខាត ដោយឥតរើសអើង។

ការជ្រើសរើសឈ្មោះ The Little Daughters of Our Mother of Inclusive Love នេះ មកដាក់ដើម្បីជំរុញសមាជិកឲ្យយកគំរូតាមព្រះនាងម៉ារី ជាមាតានៃព្រះយេស៊ូដែលទទួលស្វាគមន៍ និងឱបក្រសោបមនុស្សគ្រប់ៗគ្នា។



បច្ចុប្បន្ននេះ ក្រុមនេះមានសមាជិកពីរនាក់៖
បងស្រី Maria Chanthou
បងស្រី Maria Chantha

បច្ចុប្បននេះ ផ្ទះនៃសន្តិភាពនៅ ភូមិជិត(ឈើទាល) ចម្ងាយ១២គ.ម ពីក្រុងបាត់ដំបង ជានិវេសនដ្ឋានរបស់ក្រុមនេះ។

## សកម្មភាព ៖





កិច្ចការរបស់The Little Daughters of Our Mother of Inclusive Love មានជាអាទិ៍៖ ការអធិដ្ឋានប្រចាំថ្ងៃ អប់រំសុខភាព យកចិត្តទុកដាក់អ្នកក្រីក្រ និងថែទាំអ្នកជំងឺមជ្ឈមណ្ឌលម៉ាស្សាចាប់សរសៃ ចាក់ម្ជុលវិទ្យាសាស្ត្រ ពិនិត្យនិងសួរសុខទុក្ខអ្នកជំងឺតាមពន្ធនាគារ។

បងស្រីទទួលបន្ទុក៖ ស្រីម៉ារី ចាន់ធូ Maria Chanthou
អាសយដ្ឋានអ៊ីម៉េល៖ mtrinh812@yahoo.com
ទូរស័ព្ទទាក់ទង៖ + ៨៥៥ ៩២ ២១២២៩៣/០៩៧ ២៣៤៥៥០៥

# LA SALLE BROTHERS CAMBODIA



## ប្រវត្តិសង្ខេប ៖

ក្រុមបងប្រុសដឺឡាសាល ( De La Salle Brothers ) បានមកដល់ប្រទេសកម្ពុជាដំបូងក្នុងឆ្នាំ ១៩០៦ និងបានបង្កើតសាលារៀនមួយចំនួន ដែលគេស្គាល់ច្រើននៅទីក្រុងភ្នំពេញ។ ទោះយ៉ាងនេះក្តី ដោយសារស្ថានភាពប្រែប្រួល និង អស្ថិរភាពនយោបាយ ពួកគាត់ត្រូវបង្ខំចិត្តភៀសខ្លួនចេញពីប្រទេសនេះក្នុងឆ្នាំ ១៩៧២។

ក្រុមបងប្រុសដឺឡាសាលនៅវៀតណាមបានវិលត្រឡប់មកប្រទេសកម្ពុជាវិញប្រហែលជាបាន ៩ ឆ្នាំបន្ទាប់ពីមានការស្នើសុំពីលោកអភិបាលអេមីល ដេតម្បជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញដើម្បីជួយអប់រំអ្នកក្រីក្រ។ ប្រជាជនទាំងនេះ មានជាអាទិ៏កុមារក្រីក្រកម្ពុជា និងកុមារវៀតណាមចំណាកស្រុក។ ក្រុមបងប្រុសនេះកំពុងតែសង្ឃឹមថានឹងមិន

គ្រាន់តែអប់រំកុមារដោយផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងជួយសហគមន៍តាមមូលដ្ឋាន ឲ្យយល់នូវតម្លៃនៃអក្ខរកម្ម លេខ និងការអប់រំផងដែរ។

**ទិសដៅ៖**

ផ្ដល់ការអប់រំអំពីមនុស្ស និងភាសាខ្មែរដល់អ្នកក្រីក្រ ដោយឥតគិតថ្លៃទាំងស្រុង នៅមជ្ឈមណ្ឌលអប់រំឡាសាលពោធិ៍ធំ។ អប់រំដល់យុវជនអំពីសីលធម៌ ផ្នែកបញ្ញា រូបរាងកាយ និងសង្គម។ ជួយពួកគេឲ្យមានចិត្តចង់ទៅរៀននៅសាលារដ្ឋ ដើម្បីឲ្យ បានទៅជាពលរដ្ឋល្អ និងអ្នកកសាងសហគមន៍ខ្មែរនៅក្នុងសហគមន៍របស់ពួកគេ។ ផ្ដល់អាហារថ្ងៃត្រង់ឥតគិតប្រាក់ដល់កុមារតូចទើបចេះដើរ។ ផ្ដល់ការគាំទ្រដ៏ពិសេសសម្រាប់កុមារងាយរងគ្រោះ សម្រាប់កុមារកំព្រា និងសម្រាប់ជនពិការ។ ផ្ដល់ការអប់រំអំពីមនុស្ស និងភាសាខ្មែរដល់យុវជនមកពីក្រុមគ្រួសារក្រីក្រនៅតាមតំបន់ជនបទដោយឥតគិតថ្លៃទាំងស្រុងនៅផ្ទះក្រុមបងប្រុស ដីឡាសាល បឹងទំពុន។

## សកម្មភាព ៖

### *ក្រុមឡាសាឡេនៅពោធិ៍ធំ៖*

- កម្មវិធីសាលាមត្តេយ្យ សម្រាប់កុមារអាយុ ៤ និង៥ឆ្នាំនៅភូមិពោធិ៍ធំ មានបង្រៀនជំនាញជាមូលដ្ឋាន ដូចជា ការអាន ការសរសេរជាភាសាខ្មែរ អង់គ្លេស និង លេខ ព្រមទាំង មានផ្ដល់អាហារថ្ងៃត្រង់ឥតគិតថ្លៃដល់ពួកគេផងដែរ។
- កម្មវិធីភាសាអង់គ្លេសពិសេស សម្រាប់សិស្សបឋមសិក្សា និងវិទ្យាល័យជាមួយក្រុមបងប្រុសនិងអ្នកស្ម័គ្រចិត្តនិយាយភាសាអង់គ្លេសពីកំណើតមកពីអាមេរិក អឺរ៉ុប និង អូស្ត្រាលី ដោយបង្រៀនភាសាអង់គ្លេសដល់សិស្សនៅក្រៅម៉ោងសិក្សា និងពេលពួកវិស្សមកាល។
- កម្មវិធីថែទាំបន្ទាប់ពីសាលារៀន សម្រាប់សិស្សបឋមសិក្សា និងវិទ្យាល័យ ចាប់ពីអាយុ ៥ដល់១៨ ឆ្នាំ ដោយផ្ដល់ការបង្រៀនភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស។ ជួយពួកគេឲ្យចូលចិត្តទៅរៀននៅសាលារដ្ឋ និង រៀនឲ្យបានពូកែនៅក្នុងថ្នាក់ជាប្រចាំជាមួយជំនាញកុំព្យូទ័រ កីឡា ដូចជា បាល់ទាត់ និងបាល់ទះ។

### *ក្រុមឡា សាឡេនៅបឹងទំពុន៖*

- ក្រុមបងប្រុសជ្រើសរើសយកតែសិស្សវិទ្យាល័យឬមហាវិទ្យាល័យមកពីក្រុមគ្រួសារក្រីក្រនៅតាមតំបន់ជនបទ។



- សិស្សទៅរៀននៅសាលារដ្ឋ ឬមហាវិទ្យាល័យ។
- ក្រុមបងប្រុសបង្រៀនពួកគេនៅផ្ទះមានមុខវិជ្ជាគណិតវិទ្យា ភាសាអង់គ្លេស កុំព្យូទ័រ គីមីវិទ្យា ជាពិសេសក្រុមបងប្រុសជួយសិស្សអភិវឌ្ឍផ្នែករាងកាយ បញ្ញាស្មារតី សីលធម៌ ដោយសង្កត់ធ្ងន់លើយុត្តិធម៌សង្គម ជាពិសេសជម្រើសជាទីពេញចិត្តសម្រាប់អ្នកក្រីក្រ និងការយកចិត្តទុកដាក់ចំពោះបរិស្ថាន៕

# *LITTLE SERVANTS OF THE HOLY FAMILY*



## ប្រវត្តិសង្ខេប ៖

"Little Servants of The Holy Family" ត្រូវបានបង្កើតឡើងដោយបូជាចារ្យ សិលា ស៊ីងហ្គើ (Pierre Singer) ជាសមាជិកនៃក្រុមសាសនទូតក្រៅប្រទេសក្រុងប៉ារីស នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៤៣ ក្នុងភូមិភាគនៃទីក្រុងសេអ៊ូលប្រទេសកូរ៉េខាងត្បូង។ លោកប្រសូតនៅទីក្រុង ហេស្តង់ (Hesdin) ប្រទេសបារាំង ហើយលោកទទួលបានអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ១៩៣៥ និង ត្រូវបានចាត់ទៅប្រទេសកូរ៉េខាងត្បូងក្នុងថ្ងៃដដែលនោះ។ នៅគ្រាបង្កើតគ្រួសារនេះ ប្រទេសកូរ៉េកំពុងតែតស៊ូយ៉ាងលំបាកពីការកាន់កាប់នៃប្រទេសជប៉ុន និងសង្គ្រាមលោកលើកទី២ (សង្គ្រាមអាស៊ីប៉ាស៊ីភិច)។ ក្នុងគ្រានោះ មានបញ្ហាជាច្រើន ទាក់ទងនឹងស្បៀងអាហារ ការអប់រំ និងកំណែនទាហាន ការគំរាមកំហែងធំចំពោះជីវិត។ ដោយមើលឃើញពីស្ថានភាពបែបនេះ លោកសិលា ក៏ដឹងមុននូវសេចក្តីត្រូវការសម្រាប់ព្រះសហគមន៍ដែលនឹងបម្រើជនរងគ្រោះ អ្នករបួស អ្នកស្រេកឃ្លាន និងជនកំព្រារងទុក្ខវេទនាដែលជាអ្នកតូចតាចបំផុតក្នុងចំណោមអ្នកក្រីក្រពីសំណល់សង្គ្រាម។ លោកបូជាចារ្យយល់ឃើញថា នេះជាភារកិច្ចរបស់ព្រះសហគមន៍ក្នុងការបង្ហាញទឹកមុខសប្បុរសនៃព្រះគ្រីស្តនៅគ្រាមានវិបត្តិ។ ជាលទ្ធផល "Little Servants of The Holy Family" ត្រូវបានបង្កើតដើម្បីសម្រេចបានចក្ខុវិស័យនេះ។ បច្ចុប្បន្ននេះ

អ្នកបម្រើតូចតាចនៃគ្រួសារដ៏វិសុទ្ធ មាននៅក្នុងខេត្តពីរ គឺ Uijeongbu និង Incheon មានសមាជិកចំនួន ៤៩៨នាក់។

#### កិច្ចការបម្រើជាគ្រីស្តទូត

បច្ចុប្បន្ននេះ ក្រុមរបស់យើងមានផ្ទះចំនួន ៩៣ កន្លែងទូទាំងប្រទេសកូរ៉េ (ឆ្នាំ ២០១៤) និងចូលរួមនៅក្នុងមណ្ឌលថែទាំ និងមណ្ឌលសិក្សាបន្ទាប់ពីសាលារៀន សម្រាប់កុមារគ្មានបុព្វសិទ្ធិ និងកុមារចំណាកស្រុក កុមារមេត្តេយ្យភូមិភាគ ផ្ទះថែរក្សាមនុស្សចាស់ជរា ផ្ទះស្នាក់នៅសម្រាប់ជនពិការនិងអ្នកជំងឺ និងមន្ទីរពេទ្យគ្រួសាដ៏វិសុទ្ធសម្រាប់អ្នក ក្រីក្រ(មន្ទីរមេត្តាករុណា)។

#### បេសកកម្មក្រៅប្រទេស

បច្ចុប្បន្ននេះ មានផ្ទះចំនួន ១២ កន្លែង នៅក្នុងបេសកកម្មក្រៅប្រទេស ក្នុងប្រទេស អ៊ីតាលី បូលីវី ចិន អាហ្សង់ទីន ភីលីពីន និងវៀតណាម ដែលចូលរួមនៅក្នុងកិច្ចបម្រើព្រះសហគមន៍ ផ្តល់សេវាសុខមាលភាពសង្គម និងបេសកកម្មផ្សេងទៀត។ នៅពេលនេះ យើងកំពុង ដំណើរការចាប់ផ្តើម បេសកកម្មនៅប្រទេសកម្ពុជា។

### សកម្មភាព ៖

បច្ចុប្បន្ននេះ ក្រុមនេះកំពុងតែស្វែងរកមើលបេសកកម្មតាមដែលអាច ធ្វើទៅ បាន នៅប្រទេសកម្ពុជា ៕



# ក្រុមបងស្រីមេត្តាករុណា

## ប្រវត្តិសង្ខេប ៖

ក្រុមបងស្រីមេត្តាករុណាត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ តុលា ១៩៥០ នៅ កាល់គូតា ប្រទេសឥណ្ឌា ហើយយើងជាក្រុមគ្រួសារអន្តរជាតិនៃ គ្រឹះស្ថានសម្តេចប៉ាបសម្រាប់បព្វជិត បព្វជិតា។ គោលដៅរបស់ក្រុមគ្រួសារយើង គឺស្រឡាញ់ និងបម្រើអ្នកក្រីក្រជាងគេបំផុត នៅក្នុងចំណោមអ្នកក្រីក្រ ដោយមិនគិតដល់សាសនា និងសញ្ជាតិ។ បាវចនារបស់ក្រុមគ្រួសាររបស់យើង គឺបំពេញសេចក្តីស្រេករបស់ព្រះយេស៊ូ ដើម្បីសេចក្តីស្រឡាញ់ និងព្រលឹងវិញ្ញាណទាំងឡាយ ដោយបម្រើក្នុងការសង្គ្រោះ និងបំពេញព្រះរាជ្យរបស់ព្រះជាម្ចាស់ សម្រាប់អ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រ នៅក្នុងស្មារតីនៃសេចក្តីស្រឡាញ់ ជាទីទុកចិត្ត ប្រកបដោយការអត់ឱន និងអំណរសប្បាយ ដែលដឹកនាំពួកគេក្លាយជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះជាម្ចាស់ និងជាមួយអ្នកជិតខាង ហើយធ្វើឲ្យព្រះសហគមន៍មានវត្តមាននៅក្នុងពិភពលោកយើងសព្វថ្ងៃនេះ។



## បេសកកម្មនៃបងស្រីមេត្តាករុណានៅកម្ពុជា ៖

យើងមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី២៦ វិច្ឆិកា ១៩៩០ ជាមួយលោកបូជាចារ្យ តូនី វិន ដ្រា មីន ( Fr. Toni Vendramin, PIME ) ។ ឆ្នាំ១៩៩០-១៩៩២ យើងស្នាក់នៅផ្ទះជួលនៅទីក្រុងភ្នំពេញ ហើយបន្ទាប់មក យើងបានប្តូរទៅនៅផ្ទះវីឡាមួយនៅផ្លូវមុន្នីវង្ស។ នៅទីនោះគឺយើងមានកម្មវិធីផ្តល់អាហារូបត្ថម្ភដល់កុមារតូចៗចែកថ្នាំពេទ្យនិងចុះសួរសុខទុក្ខគ្រួសារអ្នកក្រីក្រនៅជុំវិញទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៩៤ យើងបើកទីតាំងមួយទៀតនៅចោមចៅ។ នៅចោមចៅយើងថែរក្សាអ្នកជំងឺរបេង អ្នកជំងឺទូទៅ និងអ្នកជំងឺនិងកុមារផ្ទុកមេរោគអេដស៍។ ក្រៅពីនេះយើងក៏មានកម្មវិធីចែកថ្នាំឥតគិតថ្លៃរាល់ថ្ងៃសៅរ៍ ចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងអ្នកជំងឺ។

នៅឆ្នាំ២០០១ យើងបានបើកមណ្ឌលមួយទៀតនៅសៀមរាប។ នៅទីនោះយើងមានកម្មវិធីអាហារូបត្ថម្ភសម្រាប់អ្នកក្រីក្រ និងកុមារដែលមានជំងឺ។ ហើយយើងក៏មានកម្មវិធីចុះសួរសុខទុក្ខ គ្រួសារក្រីក្រផងដែរ។





### សកម្មភាព ៖

- ដំណើរការ មណ្ឌលទាំង ៣កន្លែង ដូចជាមណ្ឌលនៅចោមចៅ មុន្នីវង្ស និង សៀមរាប ដើម្បីថែរក្សាអ្នក ជំងឺរបេង អ្នកជំងឺទូទៅ និង អ្នកជំងឺអេដស៍ពេញវ័យ និង កុមារ
- ផ្តល់ឱកាសដល់កុមារ ដើម្បី ទទួលបានការសិក្សាអប់រំ
- ចែកថ្នាំដោយឥតគិតថ្លៃ
- ចុះសួរសុខទុក្ខគ្រួសារក្រីក្រនិងអ្នកជំងឺ ៕

# ក្រុមបងស្រីព្រះបេះដូង ព្រះយេស៊ូ



## ប្រវត្តិសង្ខេប ៖

ក្រុមបងស្រីព្រះបេះដូងព្រះយេស៊ូ ជាក្រុមសាសនទូតឯកសិទ្ធិ ដែលបានបង្កើតឡើងនៅម៉ាឌ្រីត (Madrid) ក្នុងឆ្នាំ១៩៤២ដោយ ម៉ាពីឡា ណាវ៉ារ៉ូ ហ្គារីដូ (Ma. Pilar Navarro Garrido)។

**បាវចនា៖**

a. ប្រកាសដំណឹងល្អ

b. កន្លែងណាដែលគ្មានព្រះសហគមន៍ឬកន្លែងដែលគ្មានទំរង់ច្បាស់លាស់។ ចំណុចចម្បង គឺទីកន្លែងក្រីក្រ និង ទីដាច់ស្រយាល...

c. យើងត្រូវបានទទួលការត្រាស់ហៅជាអ្នកបង្ហាញវត្តមានរបស់ព្រះសហគមន៍ និងធ្វើការជាមួយសហគមន៍ គ្រីស្តបរិស័ទ

d. បម្រើព្រះរាជ្យរបស់ព្រះជាម្ចាស់។ លើកតម្កើងជីវិតក្នុងគ្រប់រូបភាព

ស្មារតីនៃក្រុម ៖ ទទួលការបំភ្លឺតាមផ្លូវវិញ្ញាណនៃសន្តអ៊ីញ៉ាស យើងឧទ្ទិសដល់ព្រះបេះដូងព្រះយេស៊ូ ដែលជាប្រភព និង ជាចំណុចស្នូលនៃជីវិតរបស់យើង និងចំណុចបង្រួបបង្រួមនៃខ្លួនយើងនិងកិច្ចការរបស់យើង។

a. ចែករំលែកបទពិសោធន៍អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់

b. ជីវិតរស់នៅនិងការបង្ហាញអំពីការឧទ្ទិសរបស់យើងគឺការផ្សាយដំណឹងល្អដោយសេចក្ដីស្រឡាញ់

## ការរស់នៅ៖

a. យើងរស់នៅជាសហគមន៍អន្តរជាតិ (តាមសេចក្ដីត្រូវការរបស់បាវចនារបស់ក្រុមយើង)

b. កម្មវិធីសហគមន៍ដែលចូលរួមប្រកបដោយសន្តិភាព នៅក្នុងជីវិតជាបព្វជិតា និងបេសកកម្មរបស់យើង

c. ចូលរួមទទួលខុសត្រូវយ៉ាងសកម្មក្នុងសហគមន៍

d. ជីវិតរស់នៅដោយសាមញ្ញតាមស្មារតីនៃក្រុមគ្រួសារ និងរស់នៅជិតស្និទ្ធជាមួយប្រជាជន

e. មានរចនាសម្ពន្ធសាមញ្ញ និងអាចបទបែនបាន ដែលងាយស្រួលសម្រប ទៅតាមបេសកកម្ម។ យើងសម្របខ្លួនឲ្យស្របតាមតម្រូវការរបស់ប្រជាជន និងស្របតាមសមត្ថភាពនិងលទ្ធភាពដែលអាចធ្វើទៅបាន។ យើងមិនធ្វើកិច្ចការធំដុំទេ។

### សមាជិកនៅកម្ពុជា ៖



យើងមាន៦នាក់ រួមមាន៖ បងស្រី ខាមិន ខាដូហ្សា, បងស្រី មីសេឡា សាន់ឆេស, សេស៊ីលីយ៉ា ហ៊ីរ៉ា, បងស្រី ហាស៊ូម៉ាទិ ហ្គាមីត, បងស្រី ហ្គូមី ហ្គាមីត, បងស្រី យូឡាដា កាប្រេ៉ា

## សកម្មភាព ៖

## ផ្នែកអប់រំ៖

- សាលាមត្តេយ្យ
- អាហារូបករណ៍(បឋមសិក្សា វិទ្យាល័យ និងសកលវិទ្យាល័យ)

- ជួយគាំទ្រដល់គ្រូបង្រៀន
- កន្លែងស្នាក់នៅសម្រាប់នារី

**សង្គមៈ**

- នៅពន្ធនាគារស្វាយសុីសុផុន (សេវាសុខភាព និងអាហារ)
- ឧបត្ថម្ភទឹកដោះគោដល់ទារក
- មណ្ឌលសុខភាព



- ផ្គត់ផ្គង់ដល់គ្រួសារក្រីក្រ

**ព្រះសហគមន៍ៈ**

- បង្រៀនអប់រំជំនឿ (យុវជន កុមារ និងមនុស្សពេញវ័យ)
- បណ្តុះបណ្តាលគណៈកម្មាក្នុងព្រះសហគមន៍
- ធ្វើដំណើររួមជាមួយគ្រីស្តបរិស័ទ

# សាសនទូតព្រះមាតាព្រះសង្គ្រោះដ៏វិសុទ្ធ (ក្រុមបងស្រី និងបងប្រុស)





## ប្រវត្តិសង្ខេប ៖

សាសនទូតព្រះមាតាព្រះសង្គ្រោះដ៏វិសុទ្ធត្រូវបានបង្កើតឡើងនៅថ្ងៃទី ៨ ធ្នូ ២០១៤ ដើម្បី បំពេញតម្រូវការរបស់មណ្ឌលសកម្មភាពនិងបេសកជននៅតាមតំបន់ដាច់ស្រយាល តាមផ្លូវវិញ្ញាណតាមរយៈការសណ្ដោសប្រណីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ សមាជិកនៃសាសនទូតព្រះមាតាព្រះសង្គ្រោះដ៏វិសុទ្ធតាមរយៈព្រះនាងម៉ារី ជាមួយព្រះនាងម៉ារី និងតាមគំរូរបស់ព្រះនាងម៉ារី ប្ដេជ្ញារស់នៅជិតស្និទ្ធជាមួយព្រះគ្រីស្តជារៀងរហូតដល់ពេល៖

- ព្រះរាជ្យរបស់ព្រះជាម្ចាស់បានសម្រេច
- បងប្អូនប្រុសស្រីរស់នៅក្នុងធម៌មេត្តាករុណាដោយភាតរភាព
- មនុស្សរាល់គ្នារស់នៅក្នុងពិភពធម៌មេត្តាករុណានៃគ្រីស្តទូត ដើម្បីនាំព្រះគ្រីស្តដល់បងប្អូនរាល់គ្នាបានស្គាល់

សាសនទូតព្រះមាតាព្រះសង្គ្រោះដ៏វិសុទ្ធមកដល់ប្រទេសកម្ពុជា នៅឆ្នាំ២០០៩ ដែលមានបងស្រីចំនួន២នាក់មកបម្រើព្រះសហគមន៍ចំនួន២ គឺព្រះសហគមន៍ ព្រះបេះដូង

ព្រះយេស៊ូ (ផ្លូវត្រី) និងព្រះសហគមន៍អរិយក្សត្រ។ បច្ចុប្បន្ន មានបងស្រីចំនួន៣នាក់និងបងប្រុសចំនួន៤នាក់កំពុងបម្រើការងារនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះក្រុមបងប្រុសមានវត្តមាននៅក្នុងព្រះសហគមន៍ដូចជា សំរោងធំ កំពង់ចម្លង តួតាំង និង ព្រែកដាច់ ចំណែកបងស្រី គឺបម្រើនៅតាមព្រះសហគមន៍២ គឺផ្លូវត្រី និងអរិយក្សត្រ។

## គោលដៅ៖

គោលដៅរបស់ក្រុមបព្វជិត-ជិតានេះ គឺជួយគ្នាទៅវិញទៅមកស្វែងរកកិច្ចការឆ្ពោះទៅរកធម៌មេត្តាករុណា និងដើម្បីប្រកាសអំពីដំណឹងល្អទៅកាន់ប្រជាជាតិនានា។ "ដើម្បីសិរីរុងរឿងរបស់ព្រះជាម្ចាស់និងការលោះបាបរបស់វិញ្ញាណ" នេះជាមូលដ្ឋានគ្រឹះនៃក្រុមគ្រួសាររបស់យើង។

## សកម្មភាពក្រុម ៖

ដើម្បីស្វែងរកធ្វើកិច្ចការឆ្ពោះទៅរកធម៌មេត្តាករុណា និងដើម្បីប្រកាសអំពីដំណឹងល្អ បងស្រីនៃក្រុមគ្រួសារនេះមិនត្រឹមតែអធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់ឡើយ ប៉ុន្តែថែមទាំងចូលរួមក្នុងសកម្មភាពប្រកាសដំណឹងល្អ ណែនាំក្រុមចម្រៀង ចូលរួមក្នុងសកម្មភាពព្រះសហគមន៍ ចុះសួរសុខទុក្ខអ្នកក្រីក្រ ជនចាស់ជរា ក្មេងកំព្រា និង មានផ្តល់ថ្នាំពេទ្យទៀតផង ៕





# ក្រុមគ្រួសារបងស្រី
# ព្រះបេះដូងព្រះយេស៊ូ ពីបាងកក



## ប្រវត្តិសង្ខេប ៖

ក្រុមគ្រួសារបងស្រីព្រះបេះដូងព្រះយេស៊ូពីបាងកកគឺជាក្រុមស្រ្តី ដែលកកើតឡើងក្នុងឆ្នាំ ១៩០០ ក្រោមការណែនាំផ្លូវវិញ្ញាណរបស់លោកបូជាចារ្យអាលុយសៀស អាល់ហ្វុងនុសដុន (Fr. Aloysius Alfonus D'hont) នៃក្រុមសាសនទូតក្រៅប្រទេសទីក្រុងប៉ារីស (MEP) ឬត្រូវបានគេស្គាល់ថាជាលោកបូជាចារ្យដុន។គាត់ជាបូជាចារ្យជនជាតិបែលហ្ស៊ិក ដែលពោរពេញដោយជំនឿនិងការគោរពស្រឡាញ់ ជាបុគ្គលគួរឲ្យស្ងើចសរសើរចំពោះការថ្វាយខ្លួនបម្រើព្រះសហគមន៍នៅក្នុងប្រទេសសៀមជាប្រទេសបេសកកម្ម។ គាត់បានណែនាំយុវនារី១២រូបដើម្បីអប់រំជាអ្នកបួស។ គាត់ចង់ថ្វាយកិច្ចការនេះដើម្បីលើកតម្កើងព្រះបេះដូងរបស់ព្រះយេស៊ូ ទៅដល់អស់អ្នកដែលព្រះអង្គស្រឡាញ់និងអាណិតជាពិសេស។

តាំងពីពេលនោះមករហូតដល់បច្ចុប្បន្ន ក្រុមគ្រួសារនេះបានឆ្លើយតបនឹងសេចក្តីត្រូវការរបស់ព្រះសហគមន៍នៅប្រទេសថៃក្នុង៤ភូមិភាគ ធ្វើការងារនៅ ៤៧កន្លែង នៅ៣៧សាលា មានផ្ទះ៤សម្រាប់ទទួលកុមារកំព្រា និងកុមារក្រីក្រ និងមានមណ្ឌលចំនួន៦ទៀតដើម្បី




ជួយដល់កិច្ចការសង្គមកិច្ច។



## សកម្មភាព៖

បច្ចុប្បន្នក្រុមបងស្រី មានចំនួន២នាក់កំពុងមានសកម្មភាពនៅក្នុងប្រទេសកម្ពុជា គឺ បងស្រី ចាន់ថាណា ស៊ីរីចាន់ថានាកុល (Sr. Chantana Sirichantanakul) និង បងស្រី សុភត្រា សុភ័ណ្ឌ (Sr. Supratra Suphon)។ ពួកគាត់កំពុងតែបម្រើការងារនៅព្រះសហគមន៍ផ្សារតូច ស្វាយប៉ាក ពោធិ៍ធំ និងក្ដីកណ្ដាល ដោយជួយមើលការខុសត្រូវនិងណែនាំលើសាលាមត្តេយ្យ និងព្រះសហគមន៍នៅទីនោះ។ កិច្ចការប្រកាសដំណឹងល្អនេះនឹងត្រូវបានសម្រេច ដោយសារមានកិច្ចសហប្រតិបត្តិការរបស់បូជាចារ្យទទួលខុសត្រូវតាមព្រះសហគមន៍ នៃភូមិភាគនីមួយៗ ដែលក្រុមបងស្រីកំពុងនៅទីនោះ៕

# បព្វជិតសាឡេស៊ានដុនបូស្កូ

## ប្រវត្តិសង្ខេប ៖

សាឡេស៊ានដុនបូស្កូគឺជាស្ថាប័នអន្តរជាតិមួយនៃក្រុមបព្វជិតធ្វើការបម្រើដល់យុវជន ជាពិសេសយុវជនដែលក្រីក្រ និងគ្មានឱកាស។ ការអភិវឌ្ឍធនធានយុវជនដោយការអប់រំ និងការអប់រំតាមបែបព្រះសហគមន៍កាតូលិក គឺជាគោលដៅចម្បងរបស់យើង ពីព្រោះយើងជឿជាក់ថា អ្វីដែលយើងកំពុងធ្វើជាមួយយុវជនគឺជាអំណោយយ៉ាងប្រសើរសម្រាប់សង្គមមនុស្ស។

ក្រុមគ្រួសារសាឡេស៊ានដុនបូស្កូ បង្កើតឡើងដោយសន្តយ៉ូហាន បូស្កូ នៅប្រទេសអ៊ីតាលី ដែលឲ្យឈ្មោះថា ជាសន្តនៃការអប់រំនៅក្នុងសតវត្សទី ១៩។ យើងមានវត្តមាននៅក្នុងប្រទេសចំនួន១៣២ប្រទេស។ យើងបានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ហើយមានសកម្មភាពនៅ ក្នុងខេត្តក្រុងចំនួន៥ ដូចជាភ្នំពេញ ព្រះសីហានុ កែប បាត់ដំបង និងប៉ោយប៉ែត។



## សកម្មភាព ៖

នៅក្នុងប្រទេសកម្ពុជា យើងជាគ្រួសារសាឡេស៊ានដុនបូស្កូ ប្តេជ្ញាខ្លួនធ្វើជាសញ្ញានិងជាអ្នកនាំនូវសេចក្តីស្រឡាញ់និងសេចក្តីមេត្តាករុណាទៅដល់កុមារកំព្រា អ្នកក្រីក្រ និងអ្នកដែលត្រូវការជំនួយ ហើយជួយយុវជនក្លាយជាបុគ្គលល្អ ស្មោះត្រង់ និងជាសម្មិទ្ធិផលធនធានសម្រាប់ប្រទេសកម្ពុជា ដោយផ្តល់អាហារូបករណ៍ផ្នែកអប់រំជាមូលដ្ឋាន និង ជួយដល់កុមារផ្ទុកមេរោគអេដស៍ មានកម្មវិធីសមភាពយែនឌ័រ និងអក្ខរកម្ម មណ្ឌលស្នាក់នៅរបស់សិស្ស និងសាលាបណ្តុះបណ្តាលបច្ចេកទេស ។









# ក្រុមគ្រួសារបងស្រីម៉ារីណុលកម្ពុជា

## ប្រវត្តិក្រុម ៖


បងស្រីAnn Sherman កំពុងអានសៀវភៅជាមួយកូនសិស្ស

ក្រុមបងស្រីម៉ារីណុល បង្កើតឡើងដើម្បីធ្វើជាសាក្សី នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និង រស់នៅជាសាសនទូតក្រៅប្រទេស។

ពួកយើងបម្រើនូវសេចក្តីត្រូវការរបស់បងប្អូនក្រីក្រហើយទីណាមានអ្នកជម្ងឺ អ្នកដែលនៅឆ្ងាយពីសង្គម ទីនោះជាបេសកម្មរបស់យើង ដោយធ្វើជា គិលានុបដ្ឋាកយិកា គ្រូពេទ្យទេវវិទូ អ្នកធ្វើការនៅក្នុងសង្គម អ្នកការពារបរិស្ថាន និងក្នុងវិស័យផ្សេងៗទៀត។ល។ បេសកម្មរបស់យើងបានចាប់ផ្តើមក្នុងឆ្នាំ១៩៩២ ខណៈពេលដែលយើងបានចាប់ផ្តើមក្រុមបងស្រីកាតូលិកនៅសហរដ្ឋអាមេរិកជាលើកដំបូង ដោយ Mollie Rogers ជាសាសនទូតក្រៅប្រទេស។ថ្ងៃនេះយើងមានសមាជិកចំនួន៥០០នាក់មកពី២៩សញ្ជាតិដែលកំពុងតែបម្រើនៅក្នុងប្រទេសចំនួន២៥ប្រទេសក្នុងពិភពលោក។


បងស្រី Helene O'Sullivan និងសិស្សកំពុងរៀនជំនាញសណ្ឋាគារ


បងស្រីLen Montiel (c) នៅគ្រាប់ពូជនៃក្តីសង្ឃឹម ចូលរួមមង្គលការបុគ្គលិក



បងស្រី Mary Little ជាមួយសិស្សនៅតួតាំង

## សកម្មភាព ៖

*កម្មវិធីពន្លកនៃក្តីសង្ឃឹមសម្រាប់មនុស្សពេញវ័យ* ៖ ក្នុងឆ្នាំ២០១៣ មានអ្នកក្រីក្រ ៥២៩នាក់ ផ្ទុកទៅដោយមេរោគអេដស៍ ហើយមានការរួមបញ្ចូលនូវដំណាក់កាលផ្សេងៗពីគ្នា ទាំងផ្នែកផ្លូវចិត្ត សង្គម និង សេដ្ឋកិច្ច ចូលទៅក្នុងពន្លកនៃក្តីសង្ឃឹម។ ២២២PLHA បានចូលមកក្នុងកម្មវិធីទាំងនេះក្នុងអំឡុងពេលដែល១៨៥PLHAបានទទួលនូវការផ្គត់ផ្គង់ចំពោះការស់នៅ ការសិក្សារហូតបញ្ចប់មហាវិទ្យាល័យ និង ការផ្លាស់ប្តូរខ្លួនឯងដើម្បីស្វែងរកចំណូលសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ ជាមួយនឹងPLHA មានកុមារឯករាជ្យចំនួន ១៣១នាក់ក៏បានទទួលនូវការផ្គត់ផ្គង់ទៅលើអាហារពេញមួយឆ្នាំ។ ច្រើនជាងនេះទៅទៀត ៤៩នៃក្រុមគ្រួសារ PLHAផ្សេងទៀតទទួលបានផ្ទះឬដីតាមលក្ខខ័ណ។ PLHA ៦៣១នាក់ ដែលជាជនក្រីក្រក្នុងមន្ទីរពេទ្យបានទទួលការថែទាំ និង ជំនួយពីពន្លកនៃក្តីសង្ឃឹម។ ពន្លកនៃក្តីសង្ឃឹមបានជួយតាមសេចក្តីត្រូវការនូវថ្លៃថ្នាំពេទ្យអាហារ និងអ្នកថែទាំនៅក្នុងមន្ទីរពេទ្យ។

*កម្មវិធីយុវជនពន្លកនៃក្តីសង្ឃឹម៖* កាលពីឆ្នាំមុន កម្មវិធីយុវជនពន្លកនៃក្តីសង្ឃឹមបានជួយកុមារកំព្រា៥៥៣៤នាក់និងកុមារឬយុវជនដែលងាយធ្លាក់ខ្លួនឈឺដោយឥទ្ធិពលនៃមេរោគ

អេដស៍។ ក្នុងករណីនេះកុមារ/យុវជន៤២១នាក់បានស្នាក់នៅតាមផ្ទះថែទាំរស់នៅជាមួយឪពុកឬម្ដាយឬជាមួយក្រុមគ្រួសារដែលពង្រីកបន្ថែមមាន៨ នាក់នៅក្នុងមណ្ឌលចិញ្ចឹមថែទាំមាន៤នាក់នៅក្នុងចំណោមនោះ គឺមានតំរូវការពិសេសជាងអ្នកជំងឺអេដស៍។ ៥០នាក់នៅតាមក្រុមផ្ទះនីមួយៗ ២៨នាក់នៅផ្ទះឆ្លងស្ពាន (ផ្ទះអ្នកដែលបានទទួលថ្នាំពន្យា និងអាចប្រកប មុខរបរចិញ្ចឹមជីវិតខ្លួនឯងបាន) និង ១៧នាក់ផ្សេងទៀត រស់នៅជាបងប្អូននៅផ្ទះឯក រាជ្យ។ បច្ចុប្បន្នមាន៤៣៦នាក់ ជាកុមារកំព្រានិងកុមារមានមេរោគអេដស៍នៅក្នុងកម្មវិធី។ ក្នុង ឆ្នាំ២០១៣ មនុស្សដំបូងដែលធំឡើងនៅក្នុងក្រុមផ្ទះនីមួយៗ បានបញ្ចប់ការសិក្សាកំរិត មហាវិទ្យាល័យផ្នែកធនាគារនិង ហិរញ្ញវត្ថុ។

*សហគមន៍សុខភាព និងកម្មវិធីការអប់រំ៖* ធ្វើនៅសង្កាត់បឹងទំពុន គាំទ្រ នូវកម្មវិធីអប់រំវ័យកុមារដំបូងកម្មវិធីភាសារអង់គ្លេស និងអក្ខរកម្ម។ មានផ្ដល់អាហារូបករណ៍ចំនួន២០០សម្រាប់សិស្សកំរិតបឋម និង សិស្សអនុវិទ្យាល័យព្រមទាំងមានកម្មវិធីសន្សំ និង កម្ចីប្រាក់ខ្នាតតូចផងដែរ។ អង្គភាពថ្មីមួយទៀតដែលផ្ដល់នូវរបៀបទាក់ទងផ្នែកសុខភាព និងអាសយដ្ឋាននៃសេវាសុខភាពដល់អ្នកក្រីក្រ។ សាលាមត្តេយ្យថ្មី ដែលទើបតែបើក ដើម្បីជួយដល់កុមារវៀតណាម និងសហគមន៍វៀតណាម ដែលមានអតិថិជនទាំងអស់សរុប៥០០នាក់។

*កម្មវិធីជំនួយដល់ការអប់រំកំរិតខ្ពស់៖* គឺមានទីតាំងស្ថិតនៅជិតសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលចំណាស់ជាងគេ និងធំជាងគេ (មាននិស្សិតចំនួន២០០០០នាក់) ដែលជាវិទ្យាស្ថានកំរិតខ្ពស់របស់រដ្ឋ ក្នុងកម្ពុជា។ កម្មវិធីនេះជួយដល់ផ្នែកភាសារអង់គ្លេសដើម្បីផ្ដល់អាហារូបករណ៍ដល់និស្សិតដែលមកពីតាមបណ្ដាខេត្តនានា អភិវឌ្ឍន៍ទ្រង់ទ្រាយបណ្ណាល័យ មានសេវាកម្មប្រឹក្សាយោបល់ផ្នែកសិក្សា ដោយផ្សារភ្ជាប់ជាមួយក្រុមអន្តរជាតិ និង ជំនួយការ បច្ចេកទេស។ ម៉ារីណុល បានផ្ដល់នូវអ្នកប្រឹក្សាយោបល់មួយរូប និងគ្រូបង្រៀន មហាវិទ្យាល័យ២រូបផងដែរ។

*វិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ* Horizons៖ ផ្ដល់កន្លែងស្នាក់សម្រាប់និស្សិត និងសិស្សបឋម និងសិស្សអនុវិទ្យាល័យ និងមានកម្មវិធីថ្មីស្ដីពីការបណ្ដុះបណ្ដាលផ្នែកសណ្ឋាគារអាស៊ាន ដោយមានការអនុវត្តដែលអាចជួយទប់ស្កាត់ការជួញដូរ និងដើម្បីជួយដល់ស្ត្រី និង កុមារីអាចផ្គត់ផ្គង់គ្រួសាររបស់ពួកគេបាន។ នេះជាយុទ្ធសាស្ត្រដើម្បីកាត់បន្ថយភាពក្រីក្រ និង ការពារប្អូនស្រីៗ ដែលងាយទទួលគ្រោះថ្នាក់ដោយសារការងារនៅតាមបាខារ៉ាអូខេ រង្គសាលផ្សេងៗ និងអន្តោប្រវេសន៍ព្រោះតែស្វែងរកការងារ។ កម្មវិធីនេះនឹងជួយដល់សិស្ស ចំនួន៥០នាក់ក្នុងមួយឆ្នាំ៕

# ក្រុមគ្រួសារបងស្រីនៃព្រះកុមារយេស៊ូ

## ប្រវត្តិសង្ខេប ៖



មិនខុស ពីក្រុមបងប្រុស Charles បងស្រីតូច ម៉ាដេលេន (Magdeleine)(1898-1989) មានឆន្ទៈរស់នៅតាព្រះបន្ទូលទាំងស្រុង។ ដោយដើរតាមមាគ៌ារបស់គាត់ បងស្រីបានចេញដំណើរទៅកាន់សាហារ៉ា (Sahara) ជា កន្លែង ដែលបងស្រីតាំងលំនៅក្នុងចំណោមពួកគេ និង បាន ក្លាយទៅជាមិត្តជិតស្និទ្ធ ជាមួយក្រុមពនេចរ ម៉ូស្លីម មួយក្រុមដែលបានទទួលស្វាគមន៍បងស្រី ទៅក្នុងការរស់នៅរបស់ពួកគេ។ ក្រុមគ្រួសារបងស្រីនៃព្រះកុមារយេស៊ូ បានប្រសូត នៅឆ្នាំ១៩៣៩។ ដោយសារលាយចម្រុះទៅក្នុងជីវិតរស់នៅធម្មតារបស់មនុស្ស ដែលទទួលស្វាគមន៍យើង ជាញឹកញាប់នៅកន្លែងមានការបែកបាក់និងគ្មានការរាប់បញ្ចូលយើងចែករម្លែកពីស្ថានភាពរស់នៅ កិច្ចការ អំណរសប្បាយ ទុក្ខលំបាក និងការតស៊ូ ជាមួយគ្នា។ ហើយជាញឹកញាប់ណាស់ គឺជាមិត្ត ភ័ក្តិរបស់យើងដែលបង្រៀនយើងឲ្យចេះមានសេចក្តីសង្ឃឹម ! ព្រះជាម្ចាស់សម្តែងព្រះអង្គផ្ទាល់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃធម្មតា នៅក្នុងពន្លឺភ្លើងដ៏តូច នៃជីវិត ដែលពេលខ្លះជាការងឿងឆ្ងល់ និងនៅក្នុងចំណងដែលភាព ខុសគ្នា បានទៅជាព្រះពរ និងគ្រាប់ពូជនៃឯកភាពសម្រាប់ពិភពលោក។

យើងជឿថា ជីវិតនឹកសញ្ជឹងគិតអំពីព្រះជាម្ចាស់ពិតប្រាកដអាចរស់នៅ ក្នុងចំណោមជីវិតធម្មតារបស់មនុស្សនៅជុំវិញពិភពលោក តាមរយៈការចែករំលែកជីវិតរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានភាពរស់នៅ កិច្ចការផ្សេងៗ និង ក្តីសុបិនរបស់ពួកគេ ដូចដែលព្រះយេស៊ូបានធ្វើនៅភូមិណាសារ៉ែត។



ខណៈដែលការអធិដ្ឋានរបស់យើងបានចាក់ឫសនៅក្នុងជីវិតធម្មតា ដូច ដែលមិត្តភាពកំពុងចេញពន្លកជាមួយអ្នកជិតខាង និងមិត្តរួមការងារ យើងទាំងអស់គ្នាសម្លឹងមើលព្រះភ័ក្ត្រ នៃព្រះជាម្ចាស់ចំពេលមានអំណរសប្បាយ និងមានឧបសគ្គ។

## សកម្មភាព ៖

យើងបានសម្រេចចិត្តបង្កើតវត្តមានក្រុមរបស់យើងនៅក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាជាប្រទេសមួយមានវប្បធម៌សម្បូរបែប និងមនុស្សធម៌។ ក្នុងឆ្នាំ ២០១២ យើងចាប់ផ្តើមសហគមន៍របស់យើងនៅក្នុង "ភូមិសុខសាន្ត" ក្នុងចំណោមក្រុមគ្រួសារដែលកើតជំងឺអេដស៍នៅចំការទៀងនៃខេត្តតាកែវ។ អាទិភាពរបស់យើង គឺត្រូវរៀនភាសាខ្មែរ និងរស់នៅជាមិត្តភាពជាមួយក្រុមគ្រួសារទាំងនេះ។ ក្នុងឆ្នាំ ២០១៤ បន្ទាប់ពីបានរស់នៅ រយៈពេលពីរឆ្នាំ យើងបានចំណាយរៀនភាសា ហើយយើងបានផ្លាស់ប្តូរ ទៅកាន់រាជធានីភ្នំពេញ ជាន្លែងដែលមានកម្មករ កម្មការិនីរោងចក្រជាច្រើន រស់នៅក្នុងស្ថានភាពលំបាកណាស់។ យើងប្រាថ្នារស់នៅក្នុងភាពសាមគ្គីគ្នា ជាមួយមនុស្សទាំងនេះ នៅជុំវិញយើង អំឡុងពេលយើងធ្វើនមស្ការប្រចាំថ្ងៃរបស់យើង។

**បរិយាយគ្រួសៗអំពីសកម្មភាពរបស់យើង៖**

- អធិដ្ឋាន និងនមស្ការព្រះកាយព្រះគ្រីស្ទ
- ចែករម្លែកជីវិតប្រចាំថ្ងៃជាមួយប្រជាជនមូលដ្ឋាន ជាពិសេស ជាមួយកម្មករ កម្មការិនីរោងចក្រ។
- ធ្វើការ និងទទួលប្រាក់ចំណូលដូចអ្នកធ្វើការធម្មតា។

## អាសយដ្ឋាន៖

ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ
ទូរស័ព្ទ៖ ០៩៧ ៨៥៩៣៩៤០
អ៊ីម៉ែល៖ sophiakj@hanmail.net

# សហជីវិនព្រះយេស៊ូ




## ប្រវត្តិសង្ខេប ៖

សហជីវិនព្រះយេស៊ូត្រូវបានអនុម័តយល់ព្រម ដោយសារលិខិត សម្តេចប៉ាប (papal bull regimini militantis Ecclesiae) នៅទី ២៧ ខែកញ្ញា ឆ្នាំ១៥៤០។ នៅគ្រានោះ សហជីវិននេះត្រូវបានរកឃើញដោយមិត្តមួយក្រុម ដែលមានចេតនាសម្រេចចិត្តបម្រើព្រះអម្ចាស់ក្រោមបដានៃព្រះឈើឆ្កាង ក្នុងការស្តាប់បង្គាប់តាមសម្តេចប៉ាប តាមរយៈការប្រកាស និងការបង្រៀនជាសាធារណៈ និង ការបម្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តាមការពិត សមាជិកម្នាក់ៗនៅក្រុមនេះ បានឆ្លងកាត់លំហាត់ខាងផ្លូវវិញ្ញាណតាមសន្តអ៊ីញ៉ាសនៅឡូយ៉ូឡា (St. Ignatius of Loyola) ក្រោមការទតមើលពីព្រះជាម្ចាស់។ សន្តបុគ្គលឧត្តុងឧត្តមនេះ ជាអតីតទាហានដែលបន្តតាមរកក្តី សុបិនរបស់គាត់បន្ទាប់ពីគាត់បរាជ័យនៅក្នុងសមរភូមិផាមភ្លូណា (Pamplona) ដែលហៀបនឹងឆក់យកជីវិតរបស់គាត់ អំឡុងពេលគាត់ងើបពីឈឺនៅ ឡូយ៉ូឡា ជាទឹកដី នៃដូនតារបស់គាត់។ នៅពេលនោះ គាត់ចាប់ផ្តើមកត់សម្គាល់ការជំរុញទឹកចិត្តយ៉ាងជ្រាលជ្រៅ នៅក្នុងព្រលឹងរបស់គាត់ហើយ នៅទីបញ្ចប់គាត់បានសម្រេចចិត្តធ្វើតាមសន្តឧត្តុង្គឧត្តមមួយចំនួនដោយការធ្វើបូជនីយេសក៏ថ្មើរជើងទៅកាន់ទឹកដីវិសុទ្ធ។ នៅតាមផ្លូវទៅកាន់ទឹកដីវិសុទ្ធរបស់គាត់ នៅក្រុងម៉ានរេសា (Manresa) សន្តអ៊ីញ៉ាស បានចំណាយពេលជិតមួយឆ្នាំរស់នៅក្នុងរូងគុហាកាន់ទុក្ខកិរិយាអធិដ្ឋាន តមអាហារ ស្រាយបាប ទូលអង្វរ ហើយដោយមាន ការជួយពីព្រះអម្ចាស់

ប្រកបដោយព្រះហឫទ័យមេត្តាករុណានៃយើង នៅទីបញ្ចប់ គាត់ទទួលបានការបំភ្លឺចិត្តគំនិត។ បន្ទាប់ពីធ្វើដំណើរទៅដល់ទឹកដីវិសុទ្ធ ស្របពេលនេះ ផែនការរបស់គាត់ ចង់ស្នាក់នៅទីនោះត្រូវបានបរាជ័យ។ គាត់មានគម្រោងការសិក្សា ដើម្បីឲ្យកាន់តែជំនាញនៅក្នុងការជួយព្រលឹងវិញ្ញាណ គាត់បានធ្វើដំណើរពីទីក្រុងមួយទៅកាន់ទីក្រុងមួយទៀត ដើម្បីសិក្សានៅប្រទេសអេស្ប៉ាញ រហូតដល់គាត់ធ្វើដំណើរទៅដល់ទីក្រុងប៉ារីស ជាកន្លែងដែលគាត់បានជួបលោកព្យែរ ហ្វារេ (Pierre Favre) និងលោក ហ្វ្រង់ស្វ័រ សាវីយេ (Francis Xavier)។ ដោយមានការណែនាំពីសន្តអ៊ីញ៉ាស លោកទាំងពីរបានឆ្លងកាត់លំហាត់ខាងផ្លូវវិញ្ញាណ ហើយនៅទីបញ្ចប់បានសម្រេចចិត្តបូជាជីវិតរបស់ពួកគាត់ដើម្បីបម្រើអ្នកក្រីក្រក្រោមបដានៃព្រះឈើឆ្កាង។ ចាប់ពីពេលនោះមក ក្រុមនៃមិត្តនេះ ត្រូវបានបង្កើត ហើយនៅទីបញ្ចប់ ដោយអនុម័តពីសារលិខិតនៃសម្តេចប៉ាប ប៉ូលទី៣ ក៏មានការទទួលស្គាល់ជាផ្លូវការថា ជាក្រុមបព្វជិតកាតូលិក ថ្មីក្នុងឆ្នាំ ១៥៤០។

ក្នុងរង្វង់នៃមុនសង្គ្រាមស៊ីវិល រហូតដល់ឆ្នាំ ១៩៧០ សហជីវិនពីរនាក់ មកពីកោះតៃវ៉ាន់ (ម្នាក់ប្រហែលជាជនជាតិតៃវ៉ាន់ និងម្នាក់ទៀតជាជន-ជាតិបារាំងធ្វើការនៅតៃវ៉ាន់) ត្រូវបានជ្រើសរើសឡើងវិញមួយទៅមួយ ដើម្បីថែរក្សា សហគមន៍គ្រីស្តបរិស័ទចិននៅទីក្រុងភ្នំពេញប្រទេសកម្ពុជា។ អំឡុងសង្គ្រាមស៊ីវិល ពួកគាត់បានចាកចេញពីប្រទេសកម្ពុជា ហើយយើងបានវិលត្រឡប់មក បម្រើព្រះសហគមន៍ និងប្រជាជនក្នុងប្រទេសនេះក្នុងឆ្នាំ ១៩៩០ ជាផ្លូវការ។



សព្វថ្ងៃនេះ យើងជាសហជីវិនព្រះយេស៊ូមានគ្នាប្រហែល ២៣នាក់ កំពុងរស់នៅ និងធ្វើការក្នុងប្រទេសកម្ពុជា ភាគច្រើននៅភូមិភាគបាត់ដំបង និង ភ្នំពេញ។

## សកម្មភាព៖

យើងផ្សារភ្ជាប់ខ្លួនយើងទៅក្នុងសកម្មភាព៖

- ផ្តល់សំណាក់ធម៌ស្ងៀមស្ងាត់។
- អ្នកណែនាំខាងផ្លូវវិញ្ញាណ។
- ជំរុញពិភពលោកគ្មានគ្រាប់មីន។
- គ្រប់គ្រងមណ្ឌលរិះគិត។
- គ្រប់គ្រងនៅក្នុងព្រះសហគមន៍ខ្លះនៅភូមិភាគបាត់ដំបង។

- បង្រៀននៅសកលវិទ្យាល័យរដ្ឋនៅទីក្រុងភ្នំពេញ។
- បើកសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការ។
- មានអង្គការ ដេអេសស៊ី (កម្មវិធីសុខភាព បណ្ណាល័យ អភិវឌ្ឍជនបទ ផ្តល់អាគារសិក្សានៅសាលារដ្ឋ ផ្តល់អាហារូបករណ៍សម្រាប់សិស្សខ្វះខាត ផ្តល់រទេះ សម្រាប់ជនពិការ)។
- ការពារបរិស្ថាន។
- ប្រារព្ធអត្តសញ្ញាផ្សេងៗនៅក្នុងភូមិភាគភ្នំពេញ។
- បង្រៀននៅទេវវិទ្យាល័យ។
- ប្រែសម្រួលឯកសារមួយចំនួន។
- ផ្តល់ជម្រក និងការពារអ្នកស្វែងរកសិទ្ធិជ្រកកោន មុនពេលពួកគេអាចរកឃើញប្រទេសទីបីបាន។
- លើកស្ទួយតម្លៃនៃគ្រហស្ថ។

ថ្មីៗនេះ យើងកំពុងចាប់ផ្តើមកម្មវិធីសាលានៅស៊ីសុផុន ខេត្តបន្ទាយមានជ័យ។ សាលានេះផ្តល់ការអប់រំជាមូលដ្ឋាន និងជំនាញបណ្តុះ បណ្តាលវិជ្ជាជីវិតមួយចំនួនដល់សិស្សនៅជុំវិញតំបន់នេះ៕



# SISTERS ADORERS, HANDMAIDS OF THE BLESSED SACRAMENT AND OF CHARITY ( AASC )



## ប្រវត្តិសង្ខេប ៖

ក្រុមបងស្រី Adorers, Handmaids of the Blessed Sacrament and of Charity (aasc) ដែលគេស្គាល់ជាទូទៅថាជាក្រុមបងស្រីនមស្ការ (Adores) បានកើតមានឡើងនៅទីក្រុង Madrid ប្រទេស អេស្ប៉ាញ ក្នុងឆ្នាំ១៨៥៦ ដោយស្ត្រីអភិជន ឈ្មោះ Maria Micaela Desmaisiers, Viscountess of Jorbalan។ បងស្រីបានកើតនៅថ្ងៃទី១ មករា ១៨០៩ នាទីក្រុង Madrid ប្រទេសអេស្ប៉ាញ។ ស្ត្រីអភិជនទាំងអស់នៅក្នុងសម័យនោះគឺរស់នៅ ក្នុងជីវិតសង្គមដ៏ទំនើប។ Maria Micaela Desmaisiers តែងតែចូលរួមក្នុងការងារមេត្តាករុណាផងដែរ។ សកម្មភាពមួយក្នុងចំណោមការងារមេត្តាករុណានោះ គឺការសួរសុខទុក្ខនៅមន្ទីរពេទ្យ (មន្ទីរពេទ្យ Jonh of God ក្នុងទីក្រុង Madrid)។ នាងបានទៅទីនោះដោយ ឆ្លងកាត់ស្ត្រីវ័យក្មេងជាច្រើន ដែលរងគ្រោះដោយអំពើពេស្យាចារ ស្ត្រីឈឺចាប់ដោយជំងឺ រោគសង្គមជាដើម។ មានតែមន្ទីរពេទ្យនេះតែមួយប៉ុណ្ណោះ ដែលព្រមទទួល

អ្នកដែលគេបោះបង់ចោលទាំងនោះនាពេលនោះដើម្បីព្យាបាល។ នាងស្តាប់រឿងក្មេងស្រីម្នាក់ក្នុងចំណោមក្មេងស្រីទាំងនោះ ដែលស្ត្រីវ័យក្មេងម្នាក់នេះបានចាញ់បោកគេ ហើយត្រូវបានបង្ខំឲ្យរួមភេទ។ Micaelaបានគិតពីអនាគតក្មេងស្រី ទាំងឡាយដែលសង្គមមិនទទួលស្គាល់។ មានពេលមួយ មន្ទីរពេទ្យបានបណ្តេញនាងៗទាំងនោះចេញ ពួកនាងត្រូវតែវិលត្រលប់ទៅរកមុខរបរដូចកាលពីមុន។ នៅទីនោះ នាងក៏នឹកឃើញពីវិធីដើម្បីជួយដល់ក្មេងស្រីអភ័ព្វទាំងនោះ។ ហេតុនេះ ក៏មាននូវគំនិតក្នុងការបង្កើតមណ្ឌលសម្រាប់ពួកគេ។ ក្នុងរយៈពេល១០ឆ្នាំ នាងបានបន្តនៅក្នុងមណ្ឌលនេះ ដោយមានការជួយពីមិត្តភ័ក្រ២ ឬ ៣នាក់ ប៉ុណ្ណោះ។ នៅគ្រាមួយ មិត្តទាំងនោះឈប់ចាប់អារម្មណ៍ដើម្បីបន្តជួយមណ្ឌលនោះទៀតនាងក៏ទទួលតែម្នាក់ឯង។ ដោយមានជំនួយខាងផ្នែកប្រធានផ្លូវវិញ្ញាណពីបូជាចារ្យនៃសហជីវិនព្រះយេស៊ូ នាងបានយល់ពីគោលបំណងរបស់ព្រះជាម្ចាស់ ហើយក៏បង្កើតក្រុមបងស្រីនមស្ការក្នុងឆ្នាំ១៨៥៦ នៅទីក្រុងMadrid។ វិស័យមេត្តាករុណារបស់ពួកយើងគឺ "ការស្រឡាញ់យ៉ាងជ្រាលជ្រៅ និងសេរីភាព" (Adores Hanmaid of the Blessed Sacrament និង សេរីភាពរបស់ស្ត្រីដែលត្រូវគេបោះបង់ ជាពិសេសសម្រាប់អ្នកដែលរងគ្រោះដោយអំពើពេស្យាចារ អ្នកដែលត្រូវបានរំលោភបំពានផ្លូវភេទ និង ក្នុងស្ថានភាពគ្រោះថ្នាក់ផ្សេងៗ)។

បងស្រីនមស្ការ នៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមក្នុងឆ្នាំ២០០៤។ បច្ចុប្បន្នមានសមាជិកចំនួន៣នាក់ (២នាក់នៅសៀមរាប និងម្នាក់នៅភ្នំពេញ)។

## សកម្មភាព៖

នៅកម្ពុជា យើងមានមណ្ឌល២សម្រាប់ស្ត្រី គឺ១នៅភ្នំពេញ និង១ទៀតនៅសៀមរាប។ អ្នកដែលរស់នៅជាមួយគ្នា គឺពោរពេញទៅដោយបញ្ហាសំខាន់ៗជាច្រើនដូចជា៖ រងនូវអំពើហិង្សាក្នុងគ្រួសារ អ្នកដែលត្រូវបានរំលោភបំពានផ្លូវភេទជាដើម...។ល។ យើងមានមណ្ឌលកាត់ដេរ នៅសៀមរាបសម្រាប់អ្នករស់នៅជាមួយយើង និងយុវនារីដែលនៅជិតខាង។ ពួកគេ ក៏បានរៀនជំនាញខ្លី ខ្លះៗផងដែរ។



*លេខទំនាក់ទំនង*

ភ្នំពេញ៖ បង ស្រី Francisca Maeda ០៩២ ៨៤៤ ៨១៧

សៀមរាប៖ បងស្រី Teresa Ogino ០១២ ៣៩១ ៥០២

# ក្រុមបងស្រី អ៊ូស៊ូលីននៃសភាពរ៉ូម៉ាំង



## ប្រវត្តិសង្ខេប ៖

ឆ្នាំ១៥៣៥ នៅប្រេស៊ីកានៅប្រទេសអ៊ីតាលី អេនជីឡា មើរីស៊ី (Angela Merici) បានបង្កើតស្ថាប័នមួយនៃសន្តី អ៊ូស៊ូឡា ជាក្រុមឧទ្ទិសដល់ព្រះនាងព្រហ្មចារិនីជាអ្នកណែនាំ។

ស្ត្រីនៅក្នុងសម័យអេនជីឡា គ្មានសិទ្ធិសេរីភាពក្នុងការជ្រើសរើសអនាគតរបស់ខ្លួនទេ។ ក្រុមគ្រួសារជាអ្នកសម្រេចចំពោះមង្គលការ ឬជាបព្វជិតា។ អេនជីឡាត្រូវជំរុញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងឲ្យមានភាពជឿជាក់លើសមត្ថភាពខ្លួនជាស្ត្រី បង្កើតឲ្យមានកន្លែងមួយសម្រាប់ជីវិត ដែលក្រោយមកក្លាយជាច្បាប់ថា ស្ត្រីព្រហ្មចារិនីរស់នៅក្នុងពិភពលោករៀបការជាមួយបុត្រារបស់ព្រះជាម្ចាស់ និង ត្រូវបានហៅថាស្មារតីភាពជាម្ដាយ។

ភាពពិតនៃសេរីភាពនៃការជ្រើសរើសរបស់ជីវិតគឺបង្កឲ្យមានជំហានផ្លាស់ប្ដូរមួយដែលឆ្ពោះទៅមុខរបស់ស្ត្រី។ គ្មានកិច្ចការណាមួយរបស់ក្រុមត្រូវបានធ្វើឡើងដាច់ឡែកតែម្នាក់ឯងបានឡើយ ពួកគាត់ត្រូវរស់នៅដូចគ្រួសារតាមច្បាប់ និង នៅក្រោមគំរូនៃមរណសាក្សីនៃព្រហ្មចារិនី។

ស្ថាប័ននេះបានរីកសាយនៅភាគខាងជើងប្រទេសអ៊ីតាលីហើយនៅសតវត្សទី១៦បានចាប់ផ្ដើមនៅប្រទេសបារាំង ដោយគ្មានការផ្លាស់ប្ដូរច្បាប់ទំលាប់ណាមួយឡើយ។ បន្តិចម្ដងៗ ក្រុមអ៊ូស៊ូលីន បានរស់នៅជាសហគមន៍ជាច្រើនរហូតដល់មានការផ្លាស់ប្ដូរជាប្រវត្តិ-សាស្ត្រមួយនៅមហាសន្និបាតត្រង់ (Council of Trent) ណែនាំឲ្យពួកគាត់រស់នៅក្នុងអារាម។ ចាប់ពីពេលនោះមក កន្លែងមួយឈ្មោះថា Order of Saint Ursula បានបង្កើតឡើងជាកន្លែងឯករាជ្យមួយសម្រាប់បព្វជិតាដែលធំជាងគេសម្រាប់ក្រុមអ៊ូស៊ូលីន ហើយក្រុមនេះបានដាក់ឈ្មោះផ្ទះរបស់ខ្លួននៅដូចៗគ្នា គឺមាននៅ ប៉ារីស ប័កដូ លីយ៉ុង និង

ទូលលូស។ ក្រុមបុត្រីនៃសន្តីអេនជីឡា បានបន្តធ្វើការងារដោយភក្តីភាពចំពោះផ្នែកអប់រំដែលជាសេចក្តីត្រូវការរបស់សង្គម។ ហើយកិច្ចការនេះ ត្រូវបានធ្វើនៅពាសពេញពិភពលោក។

នៅថ្ងៃទី១៨ សីហា ១៩៩០ អ្នកម្តាយ សន្តី ជូលាន អូប្រេយ៍ (Mother St. Julien Aubrey) នៃសហគមន៍ប្ល័ស (Blois) នៃប្រទេសបារាំងបានផ្ញើសំបុត្រអញ្ជើញប្រធានធំនៃអារាមបព្វជិតាទាំងអស់ឲ្យចូលរួមជាសហភាពតែមួយ។ ជាការឆ្លើយតប មានតំណាង ៧១ពីផ្ទះធំៗទាំងនោះដើម្បីចូលរួមកិច្ចប្រជុំនោះ។ ជាលទ្ធផល សហភាពរ៉ូម៉ាំងនៃក្រុមអ៊ូស៊ូលីនត្រូវបានបង្កើតជាផ្លូវការណ៍កាលពីខែវិច្ឆិកា ១៩០០ដែលមានទីតាំងនៅទីក្រុងរ៉ូម។

សហគមន៍អ៊ូស៊ូលីនអន្តរជាតិនៅបាត់ដំបង ក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមនៅថ្ងៃទី ២៩ កញ្ញា ២០១០ដោយបងស្រី អ៊ូស៊ូលីនមកពីតំបន់អាស៊ីប៉ាស៊ីភិចនៃប្រទេសអូស្ត្រាលី ឥណ្ឌូនេស៊ី តៃវ៉ាន់ និង ថៃ។ ក្រុមដំបូងចាប់ផ្តើមដោយបងស្រី៣នាក់មកពីឥណ្ឌូនេស៊ី តៃវ៉ាន់ និង ថៃ។ បច្ចុប្បន្នយើងមានបងស្រីចំនួន៤នាក់ ដែល២នាក់មកពីឥណ្ឌូនេស៊ី និង២នាក់មកពីថៃ។

## សកម្មភាព៖



ចាប់តាំងពីថ្ងៃទី៨ កញ្ញា ២០១៣ បងស្រីអ៊ូស៊ូលីន បានសហការជាមួយលោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ប្រាបវាលដើម្បី៖

- អប់រំជំនឿនិងបង្រៀនពីពិធីបុណ្យ
- គ្រប់គ្រងសាលាមត្តេយ្យ
- ទទួលខុសត្រូវសកម្មភាពយុវជន
- គាំទ្រដល់កិច្ចការងារក្នុងមណ្ឌលសកម្មភាព
- មណ្ឌលសិក្សា

បន្ថែមលើសនេះ មានបងស្រីម្នាក់ស្ម័គ្រចិត្តធ្វើការជាមួយមណ្ឌលសុខភាពនៅបាត់ដំបង និងបងស្រីម្នាក់ទៀតមើលការខុសត្រូវលើការងាររបស់គ្រូបង្រៀន នៅសាលាមត្តេយ្យនៃសហជីវិនព្រះយេស៊ូនៅរតនៈមណ្ឌល៕

# សាសនទូតបងប្រុសមេត្តាករុណា





## ប្រវត្តិសង្ខេប ៖

ក្នុងប្រវត្តិសាស្ត្រនៃព្រះសហគមន៍ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានបំភ្លឺចិត្តគំនិតមនុស្សជាញឹកញាប់ ដើម្បីឲ្យគេចេះបូជាខ្លួនចំពោះអ្នកក្រីក្រ និងដើម្បីចែករំលែកភាពក្រីក្ររបស់ពួកគេ។ មើលតាមទិដ្ឋភាពនេះ ព្រះវិញ្ញាណបង្ហាញវត្តមានព្រះហឫទ័យស្រឡាញ់នៃព្រះគ្រីស្តក្នុងភាពក្រីក្រ។ អ្នកម្ដាយតេរេសា (Mother Teresa BoJaxhiu) ប្រកបដោយសុភមង្គល ទទួលបានការត្រាស់ហៅឲ្យមានការបូជា ចំពោះអ្នកក្រីក្រ ដោយផ្ញើសេចក្ដីទុកចិត្តទាំងស្រុងលើព្រះហឫទ័យស្រឡាញ់នៃព្រះជាម្ចាស់។ នេះជា "ការត្រាស់ហៅក្នុងការត្រាស់ហៅ" ដែលអ្នកម្ដាយតេរេសាទទួលស្គាល់នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៤៦។ បន្ទាប់ពីទទួលបានការអនុញ្ញាត គាត់បានចាប់ផ្ដើមកិច្ចការរបស់គាត់ ជាមួយប្រជាជនក្រីក្របំផុត នៅកាល់គូតាក្នុងប្រទេសឥណ្ឌា។ ស្របពេលដែលក្រុមនេះបានដុះចេញជាពន្លកហើយ កិច្ចការនៃក្រុមនេះក៏ពង្រីកបន្ថែម។ អ្នកម្ដាយតេរេសា មើលឃើញថាមានសេចក្ដីត្រូវការដែរចំពោះក្រុមបព្វជិត ដែលចែករំលែកព្រះអំណោយទានដូចគ្នា។

គាត់បានបង្កើតសាសនទូតនៃបងប្រុសមេត្តាករុណានៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ១៩៦៣។ ជាការរួមរស់ក្នុងជំនឿ ក្រុមនេះបានទាក់ទាញយុវជនជាច្រើន។ ដើមដំបូងឡើយ ក្រុមបងប្រុសនេះស្ថិតនៅ ក្រោមការណែនាំរបស់ក្រុមបងស្រីមេត្តាករុណា និង ជាអ្នកណែនាំខាងផ្លូវវិញ្ញាណផងដែរ។ អំឡុងពេលនេះ អ្នកម្តាយតេរេសា កំពុងរង់ចាំមនុស្សម្នាក់សមនឹងទទួលភារកិច្ចជាអ្នកណែនាំនៃក្រុមបងប្រុសនេះ។ នៅខែធ្នូ ឆ្នាំ ១៩៦៥ លោកបូជាចារ្យ Ian Travers-Ball នៃសហជីវិនព្រះយេស៊ូបានមកដកបទពិសោធន៍ជាមួយក្រុមបងប្រុស។ សូម្បី តែជាសមាជិកនៃសហជីវិតព្រះយេស៊ូម្នាក់ ក៏គាត់មានឆន្ទៈពិសេសចង់ធ្វើការជាមួយអ្នកក្រីក្រផងដែរ។ ដោយមើលឃើញនូវការទាក់ទាញរបស់គាត់ចំពោះគោលការណ៍ជីវិតរបស់បងប្រុសតាមព្រះជាម្ចាស់កំណត់ទុកអ្នកម្តាយតេរេសាបានឃើញគាត់ជាចម្លើយទៅនឹងការអធិដ្ឋានរបស់អ្នកម្តាយ និងបានស្នើសុំបូជាចារ្យនេះឲ្យទទួលភារកិច្ចបន្តបណ្តុះបណ្តាល និងណែនាំក្រុមបងប្រុស។ បន្ទាប់ពីការអធិដ្ឋាន និងការរិះគិតគាត់បានយល់ព្រម និងទទួលបានការអនុញ្ញាតពីប្រធាននៃសហជីវិនព្រះយេស៊ូ។ ដោយយកឈ្មោះថា "បងប្រុសអន់ ដ្រេ(Brothers Adrew)" គាត់បានចូលរួមនៅក្នុងសាសនទូតនៃក្រុមបងប្រុសមេត្តាករុណានៅខែកុម្ភៈ ឆ្នាំ១៩៦៦។ នៅពេលមានការយល់ព្រមពីក្រសួងប្រកាសដំណឹងល្អដល់ប្រជាជាតិទាំងឡាយ អគ្គលោកអភិបាលនៃកាល់គូតា គឺលោក Albert v.D' Souza បានបង្កើតក្រុមនេះ គ្រឹះស្ថានសម្រាប់ភូមិភាគនេះ (an institute of Diocesan right) នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ១៩៦៧។ ហើយមកដល់ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៣ នៅក្នុងឋានៈជាសម្តេចប៉ាបយ៉ូហានប៉ូលទី២ សន្តអាសនៈបានទទួលស្គាល់ គ្រឹះស្ថាននេះជារបស់សម្តេចប៉ាប។

## បេសកកម្ម និង គោលដៅ

បេសកកម្មនៃក្រុមរបស់យើង គឺការរស់នៅចេះស្រឡាញ់គ្នា ដោយបូជាខ្លួនបម្រើអ្នកក្រីក្របំផុតទោះជាទីណាក៏ដោយឲ្យតែមានអ្នកក្រីក្រ។យើងមើលឃើញគោលដៅរបស់យើងជាការស្វះស្វែងដើម្បីពន្លត់នៃសេចក្តីស្រេកឃ្លាន នៃព្រះយេស៊ូនេះ៖ សេចក្តីស្រេក-ឃ្លានរបស់ព្រះអង្គ ដើម្បីសង្គ្រោះមនុស្សទាំងអស់ និងសេចក្តីស្រេកឃ្លាននៅក្នុងរង្វង់មនុស្សម្នាក់ៗ ដើម្បីភាពពេញលេញនៃជីវិត និងនៃសេចក្តីស្រឡាញ់។ សេចក្តីទាំងនេះបង្រៀនយើងជាក្រុមបងប្រុស នៅក្នុងការបំពេញសេចក្តីត្រូវការសាមញ្ញបំផុត នៃក្រុមបងប្រុស និងក្រុមបងស្រី យើងក៏កំពុងចូលរួមចំណែកដល់ការបំពេញគោលដៅចុងក្រោយរបស់ព្រះគ្រីស្ត នៃការបង្រួបបង្រួមមនុស្សទាំងអស់ដោយចិត្តស្រឡាញ់។ ជីវិតខាងផ្លូវវិញ្ញាណរបស់យើងមានការចាត់ទុកជាលក្ខណៈពិសេស ដោយការជឿជាក់ថា គឺអាចធ្វើទៅបានដើម្បី



រស់នៅដោយមានរួមរស់ដ៏ជ្រាលជ្រៅជាមួយព្រះជាម្ចាស់ ដូចដែលព្រះគ្រីស្ត បានធ្វើ សូម្បីតែស្ថិតក្នុង ចំណោមនៃសេចក្តីត្រូវការនៃជីវិតរបស់យើងជាមួយអ្នកក្រីក្រក៏ដោយ។

## សាសនទូតនៃក្រុមបងប្រុសមេត្តាករុណាក្នុងប្រទេសកម្ពុជា៖

សេចក្តីត្រូវការកាន់តែខ្លាំងឡើងៗសម្រាប់កិច្ចការធម៌មេត្តាករុណា នៅក្នុងប្រទេសកម្ពុជា ជាពិសេស សម្រាប់អ្នកត្រូវគេបោះបង់ចោល ចាស់ជរាគ្មានទីពឹង និងជនពិការ វិស័យនេះផ្តល់ឱកាសច្រើន សម្រាប់សាសនទូតនៃក្រុមបងប្រុសមេត្តាករុណា ដើម្បីធ្វើឲ្យបេសកកម្មនៃក្រុមនេះស្តែងចេញជាសកម្មភាព។ ទោះជាប្រភេទអ្វីក៏ដោយ ក៏កិច្ចការនេះគួរតែយកមកធ្វើក្នុងរបៀបមួយបែប ដែលគោរពតម្លៃដ៏ថ្លៃថ្នូរនៃអ្នកក្រីក្រ និងនាំគាត់ទៅរកការយល់ដឹងកាន់តែជ្រៅ នៃតម្លៃដ៏ថ្លៃថ្នូរនោះ។ ដូច្នេះ យើងជាក្រុមបងប្រុស សូមអះអាងថា កិច្ចបម្រើ អ្នកក្រីក្រត្រូវតែធ្វើផុសចេញពីសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ឧត្តមភាពនៃការកិច្ចបម្រើផុសចេញពីការអធិដ្ឋាន និងចិត្តសុភាពរាបសា។

## សកម្មភាព៖

១- ផ្តល់ជម្រកស្នាក់នៅបណ្តោះអាសន្នដល់កុមារដែលគេ បោះបង់ចោលរហូតទាល់តែពួកគេអាចជួបជុំគ្នាឡើងវិញជាមួយក្រុមគ្រួសារ សាច់ញាតិរបស់ពួកគេ ឬបញ្ជូនទៅទីភ្នាក់ងារ/ស្ថានប័នទទួលគេ។

២- ផ្តល់ការមើលថែរយៈពេលយូរដល់ក្មេងដែលគេបោះបង់ចោល។

៣-ផ្តល់ជម្រកបណ្តោះអាសន្នដល់យុវជនមានជំងឺអេដស៍រហូតទាល់តែមានពេលវេលាដែលគេអាចរកបានការងារនៅក្នុងសង្គម។

៤-ផ្តល់ជម្រកបណ្តុះអាសន្នដល់ក្មេងកំព្រាមានជំងឺអេដស៍ និងផ្តល់ការអប់រំដល់ពួកគេ ហើយជួយលើកទឹកចិត្តពួកគេ ឲ្យស្វះស្វែងរកជំនាញផ្ទាល់ខ្លួន។

៥- ផ្តល់ជម្រកបណ្តោះអាសន្នដល់អ្នកទីទាល់ក្រជិតស្លាប់ និងមានជំងឺផ្លូវចិត្ត រហូតដល់ពួកគេអាចរស់ជាថ្មីជាមួយសង្គម។

៦- សួរសុខទុក្ខក្រុមគ្រួសារក្រីក្រ ដើម្បីស្វះស្វែងរកកូនចៀមដែលវង្វេង។

៧- សួរសុខទុក្ខនៅពន្ធនាគារ (CCI) ដោយផ្តល់ជំនួយផ្នែកសុខាភិបាល ការចែករំលែកស្តាប់ និងលើកទឹកចិត្តពួកគេឲ្យស្វែងរកអត្ថន័យ និងសេចក្តីសង្ឃឹមពីកណ្តាលនៃភាពងងឹងរបស់ពួកគេ៕

# ក្រុមបងស្រីសាឡេស៊ានដុនបូស្កូ ឬបុត្រីនៃព្រះនាងម៉ារី ជាទីពំនឹងពំនាក់

( Figlie di Maria Ausiliatrice/FMA )



## ប្រវត្តិសង្ខេប ៖

ក្រុមបងស្រីសាឡេស៊ានដុនបូស្កូ បានបង្កើតនៅប្រទេសអ៊ីតាលី ក្នុងឆ្នាំ១៨៧២ ដោយសន្តយ៉ូហាន បូស្កូ និងសន្តីម៉ារី ដូមេនីកា ម៉ាហ្សារេឡូ។ តាមពិត ក្រុមបព្វជិតានេះមានប្រភពកំណើតពីចិត្តគំនិតរបស់លោកឪពុកដុនបូស្កូនិងភក្តីភាពរបស់អ្នកម្តាយម៉ាស្សារេឡូ ហើយក្រុមបុត្រីនៃព្រះនាងម៉ារី ជាទីពំនឹងពំនាក់ដំបូងបានបន្តទទួលបេសកកម្មពីពួកគាត់ គឺបេសកកម្មនៃភាពជាបុត្រី និងជាអ្នកពំនឹងនៃព្រះនាងម៉ារី ជាទីពំនឹងរបស់គ្រីស្តបរិស័ទ និងជាតំណាងនៃការដឹងគុណរបស់សន្តបូស្កូ ចំពោះមាតានៃព្រះជាម្ចាស់។ ក្រុមបងស្រីនេះត្រូវតែធ្វើការដើម្បីយុវនារី ដូចអ្វីដែលក្រុមសាឡេស៊ានផ្សេងទៀតបានកំពុងធ្វើ សម្រាប់យុវជនប្រុសក្រីក្រ៖ រៀបចំជីវិតពួកគេដោយបង្រៀនជំនាញធ្វើការងារ និងអប់រំចិត្តពួកគេឲ្យទៅជាគ្រីស្តបរិស័ទល្អ និង ជាពលរដ្ឋស្មោះត្រង់។ នៅសម័យនោះ ដោយមានសំណើ



ដដែលពីមនុស្សជាច្រើននៅ Turin និងជាលទ្ធផល នៃការរិះគិតផ្ទាល់របស់សន្តបូស្កូមានគំនិតបង្កើតវិទ្យាស្ថានមួយដែលអាចជួយដល់យុវនារីក្រីក្រ និង គេបោះបង់ចោលជាច្រើន។ គាត់រិះគិតនិងធ្វើ ដោយទាក់ទងជាមួយស្ថាប័នស្ត្រីផ្សេងៗ ដោយការផ្ញើសេចក្តីទុកចិត្តលើព្រះនាងម៉ារី ដោយការលើកទឹកចិត្តិសម្តេចប៉ាប Pope Pius IX និងការបំភ្លឺចិត្ត គំនិតជាច្រើនតាមរយៈសុបិននិងព្រឹត្តិការណ៍សំខាន់ៗ។ វាកើតឡើងដូច្នេះ នៅក្នុង ទីក្រុង Mornese ស្ថិតនៅលើកូនភ្នំនៃ Monferatto មានស្ត្រីវ័យក្មេងម្នាក់ឈ្មោះ ម៉ារីដូមីនីកា ម៉ាហ្សារេឡូកំពុងរស់នៅជាមួយយុវនារីមួយក្រុម ដែលមានចិត្តគំនិតដូចគាត់ បានបូជាខ្លួនគេជួយស្ត្រីវ័យក្មេងឲ្យរៀនធ្វើជំនួញ។ ស្របពេល កំពុងរៀនជំនាញកាត់ដេរ នារីទាំងនោះក៏ទទួលបានការអប់រំជំនឿជាគ្រីស្តបរិស័ទ។ លុះ សន្តដុនបូស្កូបានជួបក្រុមស្ត្រីទាំងនេះ គាត់បានទទួលស្គាល់សញ្ញាសំខាន់ពីរ ដែលបង្ហាញឲ្យឃើញពីភាពសមរម្យនៃក្រុមនេះថាជាក្រុមស្ត្រីដែលគាត់ធ្លាប់គិតទុក៖"បរិយាកាសអប់រំនៃក្រុមនេះប្រហាក់ប្រហែលទៅនឹងអ្វីដែលគាត់បានបង្កើតសម្រាប់ យុវជន ក្រីក្រនៅ Valdocco, Turin និងសមត្ថភាពជាអ្នកណែនាំរបស់ម៉ារីដូមេនីកា ម៉ាហ្សារេឡូ"។ ហេតុដូច្នេះហើយ នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ១៨៧២ ក្រុមដំបូងមានយុវនារី១១នាក់បានប្រកាសពាក្យសច្ចារបស់ពួកគេ ដោយធ្វើតាមគំរូរបស់ម៉ារីដូមេនីកា។ ដោយមានចម្លើយ "យល់ព្រម" របស់ពួកគេទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ពួកគេប្តេជ្ញាចិត្តធ្វើជាអ្នកពំនឹងរបស់ម៉ារីនៅក្នុងការណែនាំ និងមើលថែទាំយុវនារីនិងកុមារ។ ក្នុងឋានៈជាសហស្ថាបនិកនៃក្រុមនេះ ម៉ារី ម៉ាហ្សារេឡូ បូជាកំលាំងកាយចិត្តសម្រាប់ក្រុមថ្មីនេះ ដែលរង្វង់រយៈពេលពីរបីឆ្នាំ ក្រុមនេះបានរីកសាយមិន



ត្រឹមតែនៅក្នុងប្រទេសអ៊ីតាលី និងប្រទេសបារាំងប៉ុណ្ណោះទេ ថែមទាំងនៅក្នុងបណ្ដាប្រទេសជាច្រើនផងដែរនៅទ្វីបអាមេរិកភាគខាងត្បូង។ សូម្បីតែបន្ទាប់ពីអ្នកម្ដាយម៉ាហ្សារេឡូទទួលមរណភាពក្នុងឆ្នាំ ១៨៨១ ក៏ដោយ ក៏ក្រុមគ្រួសាររបស់គាត់បានបន្តបង្កើតបេសកកម្មនានានៅប៉ែកផ្សេងៗនៃទ្វីបអឺរ៉ុប ទ្វីបអាស៊ី ទ្វីបអាមេរិកខាងជើង ទ្វីបអាហ្វ្រិក និងទ្វីបអូសេអានី។ បច្ចុប្បន្ននេះ ក្រុមនេះមានបងស្រីចំនួន ១៣៦៥៣នាក់(គិតត្រឹមខែធ្នូ ឆ្នាំ ២០១១) រស់នៅក្នុងសហគមន៍ចំនួន ១៤៣៦ នៅក្នុងប្រទេសចំនួន ៩៤នៃទ្វីបទាំង៦។ ពួកគាត់ធ្វើការងារតាមសាលារៀន កន្លែងអធិដ្ឋាន និងមណ្ឌលយុវជន ផ្ទះទទួលភ្ញៀវ និងមណ្ឌលសម្រាប់កុមារអនាថា សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងបច្ចេកទេស ស្ថាប័នសម្រាប់យុវជនងាយរងគ្រោះ មណ្ឌលសម្រាប់ស្ត្រីមានវិបត្តិ និងគ្លីនីកពេទ្យ។ ក្រុមបងស្រីសាឡេស៊ានបានដល់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ហើយបច្ចុប្បន្ននេះ (២០១៤) មានបងស្រីសាឡេស៊ាន ២៤នាក់ មាន១១សញ្ជាតិ កំពុងបម្រើព្រះសហគមន៍ និងយុវជនកម្ពុជា។

## សកម្មភាព៖

ដោយមើលឃើញពីតម្រូវការអប់រំ ការលើកកម្ពស់តម្លៃមនុស្សជាតិនិងការអភិវឌ្ឍយុវជន ក្រុមបងស្រីបានបង្កើតមណ្ឌលយុវជនារីដំបូងនៅទួលគោក ដែលពេលនោះទួលគោកជាខណ្ឌសំបូរទៅដោយស្ត្រីពេស្យានៅរាជធានីភ្នំពេញ។ មណ្ឌលផ្ដល់កន្លែងកំសាន្តនិងសកម្មភាពយុវជន មេរៀនជាភាសាខ្មែរ ភាសាថៃ និងភាសាអង់គ្លេស ការអប់រំអំពីតម្លៃជីវិត ការប្រកួតកីឡានិងសិល្បៈ ហើយក្រោយមកមានបង្រៀនវិជ្ជាជីវៈកាត់ដេរ និងកុំព្យូទ័រ។

នៅពេលមានយុវនារីប្រហែលមួយរយនាក់ចាប់ផ្តើមមករៀនយ៉ាងទៀងទាត់ ហើយមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូសម្រាប់ស្ត្រីបានកសាងក្នុងឆ្នាំ ១៩៩៣។ មណ្ឌលនេះក៏បានផ្តល់កន្លែងស្នាក់នៅសម្រាប់សិស្សមកពីភូមិឆ្ងាយៗផងដែរ។ សាលាមត្តេយ្យមួយបាន បង្កើតឡើងក្នុងឆ្នាំ ១៩៩៤។ ឆ្នាំ ១៩៩៧ បង្កើតមណ្ឌលទីពីរ មានកន្លែងស្នាក់នៅសម្រាប់យុវនារី នៅក្នុងភូមិ ទឹកថ្លា (ខណ្ឌសែនសុខ) ហើយសិស្សរៀនវគ្គកាត់ដេរត្រូវបានផ្លាស់ទៅកាន់ទីនោះ។ សាលាមត្តេយ្យ និងបឋមសិក្សាត្រូវបានបង្កើតបន្ថែម និងមានវគ្គសិក្សាផ្នែកធ្វើម្ហូប និងវិជ្ជាមេផ្ទះ។ ក្នុងឆ្នាំ ២០០១ សាលាដុនបូស្កូ ភូមិច្រេស បង្កើតឡើងសម្រាប់កុមារក្រីកនៅជាយក្រុងភ្នំពេញ និងនៅឆ្នាំ ២០០២ ក្រុមបងស្រីបានបើកមណ្ឌលអក្ខរកម្មនិងកាត់ដេរ នៅក្នុងខេត្តបាត់ដំបងដើម្បីបង្រៀនជំនាញ និងការពារស្ត្រីឲ្យរួចពីការជួញដូរ ឬធ្វើអាជីវកម្ម ជាពិសេសនៅតាមព្រំដែនកម្ពុជា-ថៃ។ ផ្ទះស្នាក់នៅសន្តឡៅរ៉ានៅទួលគោកបានបើកនៅឆ្នាំ២០០៤ដើម្បីផ្តល់សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ចំពោះយុវនារីដែលគេបោះបង់ចោល ឬអ្នកដែលស្ថិតក្នុងក្រុមគ្រួសារលំបាកយ៉ាប់យឺន។ ទន្ទឹមគ្នានោះដែរ សាលាបឋមសិក្សានៅទឹកថ្លា បានពង្រីកទៅជាសាលាអនុវិទ្យាល័យ ហើយបានបើកឆ្នាំសិក្សានៅខែតុលា ឆ្នាំ២០១៤។ បន្ថែមទៅនឹងកិច្ចការបម្រើទាំងនេះ យើងក៏កំពុងជួយអប់រំជំនឿដល់បណ្តាជនផងដែរ៕

# សាសនទូតបព្វជិតនៃសន្តដូមីនីក



## ប្រវត្តិសង្ខេប ៖

- សន្តដូមីនីកជាស្ថាបនិករ (១១៧០-១២២១)
- លោកបានបង្កើតក្រុមអ្នកផ្សព្វផ្សាយដំណឹងល្អ (Friars of Preachers) ឆ្នាំ ១២១៦
- លោកបានបង្កើត Holy Rosary Province ឆ្នាំ ១៥៨៧
- លោកបានបង្កើតសាសនទូតបព្វជិតានៃសន្តដូមីនីកឆ្នាំ ១៨៨៧

សាសនទូតរបស់យើងដំបូងគឺនៅប្រទេសចិនចាប់ផ្តើមពីឆ្នាំ ១៨៨៧ ដល់ឆ្នាំ ១៩៥២ ជាបេសកកម្មមួយដែលជួយថែរក្សាក្រុមស្ត្រីអនាថា។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៣៣ ធម្មនុញ្ញនៃក្រុមរបស់យើងបានដាច់ចេញពីក្រុម Holy Rosary Province ហើយត្រូវបានប្រកាសឲ្យប្រើជាផ្លូវការក្នុងឆ្នាំ១៩៣៤ រួចយើងបានចាប់ផ្តើមបេសកកម្មជាក្រុមបព្វជិតានៃសន្តដូមីនិក។
ចាប់ពីឆ្នាំ ១៩៣៤ រហូតមកដល់បច្ចុប្បន្ន ក្រុមបព្វជិតានៃសន្តដូមីនិក មានវត្តមាននៅ

ប្រទេស ចិន

ដូចជា ភីលីពីន



ព័រទុយហ្កាល់ អេស្ប៉ាញ សហរដ្ឋអាមេរិច ទីក្រុងរ៉ូម ឈីលី ជប៉ុន តៃវ៉ាន់ ហ្គូអាំ កូរ៉េ ថៃ កម្ពុជា មីយ៉ាន់ម៉ា និង វៀតណាម ដើម្បីប្រកាសព្រះបន្ទូលដំណឹងល្អតាមវិធីផ្សេងៗ។ សាសនទូតនៃក្រុមរបស់យើងប្រកាសដំណឹងល្អ នៅតាមបណ្តាលប្រទេសនានាដោយមានសកម្មភាព ៖ ជួយក្មេងកំព្រា ផ្ទះសម្រាប់ចាស់ជរា មានមណ្ឌលថែទាំសុខភាព មន្ទីរពេទ្យ មានផ្តល់ការអប់រំ និង កិច្ចការប្រកាសដំណឹងល្អ។

"ការបញ្ជូនបន្តនៃក្រុមដូមេនីក ការចែកចាយព្រះបន្ទូលបានចាត់ទុកជាសកម្មភាពខាងផ្លូវវិញ្ញាណជានិច្ច សូម្បីតែសកម្មភាពនឹកសញ្ជឹងគិតអំពីព្រះជាម្ចាស់ក៏ដោយ។ គុណតម្លៃនៃការចែកចាយព្រះបន្ទូលទទួលបានព្រះអំណោយទាននៃការរីកចម្រើនក្នុងព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់"។ ( Fr. P. Murray )

"ក្រុមផ្សព្វផ្សាយដំណឹងល្អ" បានបង្កើតជាពិសេសសម្រាប់ ការចែកចាយព្រះបន្ទូល និងសម្រាប់សង្គ្រោះព្រលឹងវិញ្ញាណ។ ការប្រកាសព្រះបន្ទូលដំណឹងល្អ បានក្លាយជាកំលាំងស្នូលជំរុញជីវិតសន្តដូមេនីកជាបិតារបស់យើង។ លោកបានបូជាពេញមួយជីវិតរបស់លោក ចំពោះបេសកកម្មនៃការប្រកាសដំណឹងល្អ។ លោកបានបង្កើតចក្ខុវិស័យនៃក្រុមអ្នកផ្សព្វផ្សាយដំណឹងល្អ ត្រូវធ្វើដំណើរទៅគ្រប់ទីកន្លែងដែលមនុស្សចង់ស្តាប់និងចង់ស្គាល់ដំណឹងល្អនេះ។ លោកក៏ជឿថា ដើម្បីឲ្យការផ្សព្វផ្សាយនេះមានសេចក្តីពិតជាក់

ស្តែង អ្នកប្រកាសដំណឹងល្អត្រូវការការគាំទ្រពីសហគមន៍មួយ ដែលពួកគេអាចអធិដ្ឋានជាប្រចាំ និងជីវិតជាស្នូម ដើរសុំទានសម្រាប់សេចក្តីត្រូវការរបស់សហគមន៍ និងព្រះបន្ទូលដែលត្រូវផ្សព្វផ្សាយ។ សន្តដូមីនីកជាបិតារបស់យើងជឿថា កិច្ចការនេះជាការផ្សព្វផ្សាយ



ដ៏វិសុទ្ធ ។ ចាប់តាំងពីពេលនោះមក មនុស្សគ្រប់ជំនាន់បានដើរលើមាគ៌ាតែមួយ ហើយនៅក្នុងសម័យនេះ ព្រះអំណោយទាននៃសន្តដូមីនីក ជាការបញ្ជូនបន្តដ៏មានជីវិត។

## សកម្មភាព ៖

យើងមានកិច្ចការណែនាំព្រះសហគមន៍របស់យើង ដោយសហការជាមួយព្រះសហគមន៍សន្តមីកាអែលក្រុងព្រះសីហនុនៃភូមិភាគភ្នំពេញ។ កិច្ចការយើងមាន៖

- ទទួលខុសត្រូវសាលាមត្តេយ្យនៅកោះខ្យង បឹងតាព្រហ្ម និង ត្រែងត្រយឹង។

- ទទួលខុសត្រូវអប់រំជំនឿដល់កុមារ និងយុវជននៅកោះខ្យង បឹងតាព្រហ្ម ត្រែងត្រយឹង ស្រែអំបិល និងព្រះសហគមន៍សន្តមីកាអែលក្រុងព្រះសីហនុ ព្រមទាំងបម្រើព្រះសហគមន៍ និងចាត់ចែងពិធីបុណ្យផងដែរ។
- ផ្តល់មេរៀនផ្នែកដូរ្យតន្ត្រី (ហ្គីតា ព្យ៉ាណូ វីយ៉ូឡុង...)។

អប់រំយុវជននិងកុមារអំពីតម្លៃនៃជីវិត៕